អដ្ឋកថា ព្រះសុត្តន្តបិដក

សារត្ថប្បកាសិនី

ឆដ្ឋភាគ

ភាគ ៣៤

ពុទ្ធសករាជ ២៥៥៦

អដ្ឋកថា ព្រះសុត្តន្តបិដក

សំយុត្តនិកាយ

ឈ្មោះ

សារត្ថប្បកាសិនី

ភាគ ៣៤

ខន្ធវារវគ្គ ឆដ្ឋភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

ខន្ធសំយុត្ត អាយតនសំយុត្ត និដ្ឋសំយុត្ត

អដ្ឋកថាកែ ៧៣ សូត្រ

ខន្ធវារវគ្គ

ឆដ្ឋភាគ មាន ៣ សំយុត្ត

១-ខន្ធសំយុត្ត	មាន ០៥ វគ្គ
	ព្រះអដ្ឋកថាកែសេចក្តី ២១ សូត្រ
២-អាយតនសំយុត្ត	មាន ០៤ វគ្គ
	ព្រះអដ្ឋកថាកែសេចក្តី ០៩ សូត្រ
៣-ធិដ្ឋិសំយុត្ត	មាន ០៤ វគ្គ និង ១០ សំយុត្ត
	ព្រះអដ្ឋកថាកែសេចក្តី ៤៣ សូត្រ

រួមក្នុងឆដ្ឋភាគនេះ មាន ០៣ សំយុត្តធំ

ស្មើនិង ១៣ វគ្គ និង ១០ សំយុត្ត

ព្រះអដ្ឋកថាចានកែសេចក្តីដែល

លំចាកសរុបមានចំនួន ៧៣ សូត្រ

ស្រៈនិងសញ្ញា

Signes et accents:

ខ្មែរ Cambodgien	◌	◌	◌	◌	◌	◌	◌	◌
ខ្ទរ Romain	*a*	*ā*	*i*	*ī*	*u*	*ū*	*e*	*o*
សៀម Siamois	◌	◌	◌	◌	◌	◌	◌	◌
លាវ Laotien	◌	◌	◌	◌	◌	◌	◌	◌
សង្ហឡ Cinghalais	◌	◌	◌	◌	◌	◌	◌	◌
ភូមា Birman	◌	◌	◌	◌	◌	◌	◌	◌

ស្រៈពេញតួ
Voyelles.

ខ្មែរ Cambodgien	អ	អា	ឥ	ឣ	ឧ	ឩ	ឯ	ឱ
ឡាតាំង Romain	a	ā	i	ī	u	ū	e	o
សៀម Siamois	อ	อา	อิ	อี	อุ	อู	เอ	ไอ
ឡាវ Laotien	ະ	າ	ິ	ີ	ຸ	ູ	ເ	ໄ
សិង្ហឡ Cinghalais	අ	ආ	ඉ	ඊ	උ	ඌ	ඒ	ඔ
ភូមា Birman	အ	အာ	ဣ	ဤ	ဥ	ဦ	ဧ	ဩ

ព្យញ្ជនៈ

Consonnes.

ខ្មែរ Cambodgien	ក	ខ	គ	ឃ	ង
ឡាតាំង Romain	k	kh	g	gh	ṅ
សៀម Siamois	ก	ข	ค	ฆ	ง
ឡាវ Laotien	ກ	ຂ	ຄ	ຆ	ງ
ឆកដា Cinghalais	ක	ඛ	ග	ඝ	ඞ
ភូមា Birman	က	ခ	ဂ	ဃ	င

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ឡាវ Romain	c	ch	j	jh	ñ
សៀម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຫຼ	ຍ
សិង្ហល Cinghalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ឡាវ Romain	c	ch	j	jh	ñ
សៀម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຝ	ຍ
សិង្ហឡ Singhalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ឡាតាំង Romain	c	ch	j	jh	ñ
ស្យាម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຫຼ	ຍ
សិង្ហឡ Cinghalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ឡាវ Romain	c	ch	j	jh	ñ
សៀម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຝ	ຍ
សិង្ហឡ Singhalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ឡាវ Romain	c	ch	j	jh	ñ
សៀម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຝ	ຍ
សិង្ហឡ Singhalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ឡាវ Romain	c	ch	j	jh	ñ
សៀម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຝ	ຍ
សិង្ហល Singhalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ពាក្យផ្តើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

សុត្ត *បានដល់ ឧកតោវិកត្ត និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

គេយ្យ *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

វេយ្យាករណ *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

គាថា *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

ឧទាន *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងដោយសោមនស្សញ្ញាណ ។*

ឥតិវុត្តក *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមឡើងដោយពាក្យថា សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

ជាតក *គឺ ជាការសម្តែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

អព្ភូតធម៌ *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

វេទល្យ *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបានទូវសេចក្តី*

រីករាយ និងសួរជាបន្ត ។ ៗ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាមឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែលបណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញុំាងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ។ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ។ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រទិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្តាត់តគ្នាមកតាមលំដាប់ មានធនូៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ អាចរិយវាទ វាទៈរបស់អាចារ្យផ្សេង ។ តាំងអំពីថ្នាក់ជីកា អនុជីកា និង បុព្វាចារ្យជំនាន់ក្រោយ ។ ។

៤ អត្តនោមតិ ការគិតយើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រកេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធន្លុះក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្ម-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមវៀបវៀងព្រះអដ្ឋកថា

និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-
ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើម
បារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអគ្គសាក្សី ត្រាស់ព្រះអភិធម្ម-
កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ
ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម្មវិន័យ គឺ ៖

១ ភិក្ខុទុកជាក់អំបិលក្នុងក្អាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេរៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបាន
ធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា
ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ
គួរ ។

៨ ភិក្ខុផឹកស្រាខ្យាយ ៗ គួរ ។

៩ កិក្ខុក្រាលសំពត់និសីទន:ដែលមិនមានជាយ គួរ ។

១០ កិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកជាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌក: បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោកវាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគ:ធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរ: ៧០០ អង្គ ក្នុងចំណោម កិក្ខុ ១.២០០.០០០ អង្គ គឺ (ដប់ពីរសែន) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរ: គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

កិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយ គ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណ: គ្រាបានពួកដែលជាទុព្វលវ:ដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្អាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិក: និងឯកព្យាហារិក: ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិក:នោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទ: និងពហុលិយ: ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិក: ដែលបែកចេញមកពីនិកាយគោកុលិក: ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងវាងនិកាយពហុលិយ: នោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសកវាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិក:ដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិក:ជើមមួយ ក៏បានជា

ជ្រាំមួយត្រកូល ។ ក្នុងពុទ្ធសកវាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសក: និងវជ្ជីបុត្តក:កើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តា អាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយ: ១ ភទ្រយានិក: ១ ឆន្នាគារិក: ១ សម្មិតិយ: ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តក: ។ ក្នុងពុទ្ធសកវាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មុត្តរិក:កើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសក:ទៀត ។ កាលនិកាយកស្សបិក:ទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិក:ផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិក:ទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសកវាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែក ចេញមកពីត្រកូលអាចារ្យមហាសង្ឃិក:ទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បី ជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣



កិកូដ៏លាមកទាំង៦ពួក ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំង៦ពួកបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

(ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)

ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះកិកូមានាមថា ពុទ្ធឃោសៈដូចគ្នា បានអាចនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ពាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអាចនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ជីវ ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ។ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹម ត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះ ស្វាធ្យាយហើយ ក៏ជឿថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយ បានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ។ ព្រាហ្មណ៍ កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា ***ពុទ្ធមន្ត*** *ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។*

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនា បកវណ៌ឈ្មោះ ***ញាណោទ័យ*** *ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបកវណ៌ និងគម្ពីរបវិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលី ព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)*

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះកិច្ចសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបានទិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មានន័យដទៃទៀតថា (សិរិនិវាស) ខ្លះ (សិរិកុថៈ) ខ្លះ (សិរិកូដ្ឋៈ) ខ្លះ ពុទ្ធសកវាជ (៩៥២-៩៧៤) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះកិច្ចសង្ឃក្នុងមហាវិហារនៅក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្សៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោស:បានរចនាបកវណ៌ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោស:នោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោស:ក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោស:ក៏បានទាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះកិក្ខុសង្ឃ ព្រះកិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យនាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការបានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡ:មកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បជា-នយរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាកាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកកាសាមគធៈ ។

អដ្ឋកថាក្នុងកាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាកាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងកាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកនយព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាកាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាកាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថា ទាំងអស់ មានវាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិនយបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចបករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំង ប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធាន ហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេស ផ្សេង ។ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បាន សម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្ឆាត ហ៊ិន	ឧបាសក នាក់ ម៉ៅ
ឧបាសក ទុំ ទូន	ឧបាសក ហុក សឺងហួត
ឧបាសក ជឹម ជំនិត	ឧបាសក កើត ទិត្យ
ឧបាសក សន ម៉ារឌី	ឧបាសក ហាយ ចំរើន
ឧបាសក អ៊ឹម រ៉ៃយ៉ា	ឧបាសក សុក្រ ហ៊ិត
ឧបាសក សោម រតនៈ	ឧបាសក សំ ឆាយ
ឧបាសក ម៉ៅ ផុន	ឧបាសក ជា ស៊ីបាន
ឧបាសិកា ថាប់ លឿម	ឧបាសិកា ហាយ សារ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី	ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង	ឧបាសិកា ប៊ុត សេដាដួង
ឧបាសិកា ប៉ែន រមណី	

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គមិន្ទោ	នូវ ប៊ូរ៉ា	ប្រធានអាស្រម
ព្រះភិក្ខុចិត្តរក្ខិតោ	សំ សម្បត្តិ	ធម្មាចារ្យ
ព្រះភិក្ខុធម្មប្បញ្ញោ	ឆុំ សាវឿន	ធម្មាចារ្យ
ព្រះភិក្ខុវរធម្មោ	ផុត តៅ	ធម្មាចារ្យ

សាមណេរ កោវិនោ ឡោះ សូវ៉ៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ក្លាត ហ៊ាន	ឧបាសក ហាយ ចំរើន
ឧបាសក ហុក សីងហួត	ឧបាសក អ៊ឹម រ៉ៃយ៉ា
ឧបាសក ឈួន សំណាង	ឧបាសក ឃឿម សារ៉ែន

បត្តិឋានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

ឧទ្ទិសថ្វាយ និងគោរពជូន:

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃយភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

មាតិកាធម៌

ឈ្មោះធម៌ ទំព័រ

ចុទ្ទបណ្ណាសកៈ
ខន្ធសំយុត

អន្តវគ្គ
អដ្ឋកថា អន្តសូត្រ ន័ ១ ១
អដ្ឋកថា ទុក្ខសូត្រ ន័ ២ ២
អដ្ឋកថា សកាយសូត្រ ន័ ៣ ៣
អដ្ឋកថា បរិញ្ញេយ្យសូត្រ ន័ ៤ ៤
អដ្ឋកថា សមណសូត្រ ន័ ៥ ៥

ធម្មកថិកវគ្គ
អដ្ឋកថា អវិជ្ជសូត្រ ន័ ១ ៦
អដ្ឋកថា វិជ្ជាសូត្រ ន័ ២ ៧
អដ្ឋកថា ធម្មកថិកសូត្រ ន័ ៣ ៨
អដ្ឋកថា ធម្មកថិកសូត្រ ន័ ៤ ៩
អដ្ឋកថា ពន្ធនសូត្រ ន័ ៥ ១០
អដ្ឋកថា បរិមុចចិត្តសូត្រ ន័ ៦-៩ ១១
អដ្ឋកថា សីលសូត្រ ន័ ១០ ១២
អដ្ឋកថា សុតវាសូត្រ ន័ ១១ ១៤
អដ្ឋកថា កប្បសូត្រ ន័ ១២ ១៥

អដ្ឋកថា កប្បសុត្រ	ន ១៣	១៦

អវិជ្ជាវគ្គ

អដ្ឋកថា សមុទយធម្មសុត្រ	ន ១	១៧

កក្កុឡវគ្គ

អដ្ឋកថា កក្កុឡសុត្រ	ន ១	១៨

ឥដ្ឋិវគ្គ

អដ្ឋកថា អដ្ឋត្តិកសុត្រ	ន ១	១៩
អដ្ឋកថា ឋតំមមសុត្រ	ន ២	២០
អដ្ឋកថា ឋសោអត្តសុត្រ	ន ៣	២១
អដ្ឋកថា អានន្ទសុត្រ	ន ១០	២២

រាធសំយុត្ត

បឋមវគ្គ

អដ្ឋកថា មារសុត្រ	ន ១	២៤
អដ្ឋកថា សត្តសុត្រ	ន ២	២៦
អដ្ឋកថា ភវនេត្តិសុត្រ	ន ៣	២៧
អដ្ឋកថា បរិញ្ញេយ្យសុត្រ	ន ៤	២៨
អដ្ឋកថា បឋម.....សុត្រ	ន ៥	២៩

ទុតិយវគ្គ

អដ្ឋកថា មារសុត្រ	ន ១	៣០

អដ្ឋកថា មារធម៌សូត្រ	ទី ២	៣១

អាយាចនវគ្គ

អដ្ឋកថា អាយាចនវគ្គ	ទី ៣	៣២

ឧបនិសិន្នវគ្គ

អដ្ឋកថា ឧបនិសិន្នវគ្គ	ទី ៤	៣៣

ទិដ្ឋិសំយុត្ត

សោតាបត្តិវគ្គ

អដ្ឋកថា ឱតសូត្រ	ទី ១	៣៤
អដ្ឋកថា ឱតំមមសូត្រ	ទី ២-៤	៣៦
អដ្ឋកថា ឧត្តិដ្ឋសូត្រ	ទី ៥	៣៨
អដ្ឋកថា កកុធោសូត្រ	ទី ៦	៤២
អដ្ឋកថា ហេតុសូត្រ	ទី ៧	៤៥
អដ្ឋកថា មហាទិដ្ឋិសូត្រ	ទី ៨-១០	៤៨
អដ្ឋកថា អដ្ឋាឱសូត្រ	ទី ១១-១៨	៥៩

ទុតិយគមនាទិវគ្គ

អដ្ឋកថា រូបីអត្តសូត្រ	ទី ១៩	៦១
អដ្ឋកថា អរូបីអត្តសូត្រ	ទី ២០	៦២
អដ្ឋកថា រូបីចអរូបីអត្តសូត្រ	ទី ២១	៦៣
អដ្ឋកថា នេវរូបីនា.....សូត្រ	ទី ២២	៦៤
អដ្ឋកថា ឯកន្តសុខីសូត្រ	ទី ២៣	៦៥

អដ្ឋកថា ឯកន្តទុក្ខីសូត្រ	ធី ២៤	៦៦

តតិយបេយ្យាល

អដ្ឋកថា តតិយបេយ្យាល	រួម ២៦ សូត្រ	៦៧

ចតុត្ថបេយ្យាល

អដ្ឋកថា ចតុត្ថបេយ្យាល		៦៨

ឱក្កន្តសំយុត្ត

អដ្ឋកថា ចក្កុសុត្តាធិសូត្រ	ធី ១-១០	៦៩

ឱឃ្បាទសំយុត្ត

អដ្ឋកថា	សូត្រធី ១-១០	៧១

កិលេសសំយុត្ត

អដ្ឋកថា	សូត្រធី ១-១០	៧២

សារីបុត្តសំយុត្ត

អដ្ឋកថា	សូត្រធី ១-៩	៧៤
អដ្ឋកថា សូចិមុខីសូត្រ	ធី ១០	៧៥

នាគសំយុត្ត

អដ្ឋកថា សុទ្ទកសូត្រ	ធី ១	៧៩
អដ្ឋកថា សូត្រ	ធី ២ ជាដើម	៨០

សុបណ្ណសំយុត្ត

អដ្ឋកថា សុទ្ទកសូត្រ	ន័ ១	៨២
អដ្ឋកថា មារតិសូត្រ	ន័ ២	៨៣

គន្ធព្វកាយសំយុត្ត

អដ្ឋកថា សុទ្ទកសូត្រ	ន័ ១	៨៥
អដ្ឋកថា មូលកឧទ្ទានាសូត្រ	ន័ ៣	៨៦

វលាហកសំយុត្ត

អដ្ឋកថា ឧទេសនាសូត្រ	ន័ ១	៨៧
អដ្ឋកថា សូត្រ	ន័ ១៣-៥២	៨៨
អដ្ឋកថា សូត្រ	ន័ ៥៣	៨៩
អដ្ឋកថា សូត្រ	ន័ ៥៤	៩០
អដ្ឋកថា សូត្រ	ន័ ៥៥	៩១
អដ្ឋកថា សូត្រ	ន័ ៥៦	៩២

វច្ឆគោត្តសំយុត្ត

អដ្ឋកថា វច្ឆគោត្តសំយុត្ត		៩៥

សមាធិសំយុត្ត

អដ្ឋកថា សមាធិសមាបត្តិ	ន័ ១	៩៦
អដ្ឋកថា ឋិតិសូត្រ	ន័ ២	៩៧
អដ្ឋកថា វុដ្ឋានសូត្រ	ន័ ៣	៩៨
អដ្ឋកថា កល្យិតសូត្រ	ន័ ៤	៩៩

អដ្ឋកថា	អារម្មណសូត្រ	ន័ ៥	១០០
អដ្ឋកថា	គោចរសូត្រ	ន័ ៦	១០១
អដ្ឋកថា	អភិនីហារសូត្រ	ន័ ៧	១០២
អដ្ឋកថា	សក្កច្ចការីសូត្រ	ន័ ៨	១០៣
អដ្ឋកថា	សាតច្ចការីសូត្រ	ន័ ៩	១០៤
អដ្ឋកថា	សប្បាយការីសូត្រ	ន័ ១០	១០៥

សារត្ថប្បកាសិនី

អដ្ឋកថា ខន្ធវារវគ្គ

ខន្ធសំយុត្ត ចូឡបណ្ណាសកៈ

លេខ ៣៤

អន្តវគ្គទី ๑

អ ដ្ឋ ក ថា

អន្តសូត្រទី ๑

គប្បីជ្រាបវិនិច្ឆ័យក្នុង ***អន្តសូត្រទី*** *๑ ដូចតទៅនេះ ៖*

[๑] *បទថា* ***អន្តោ*** *បានដល់ ចំណែកទាំងឡាយ ។ សូត្រនេះ ព្រះ-មានព្រះភាគត្រាស់ តាមអធ្យាស្រ័យរបស់វេនេយ្យសត្វដែលនឹងត្រាស់ដឹងបាន ដោយពាក្យថា* ***អន្តោ*** *ដោយទ្រង់ប្រកបខន្ធ ៥ ចូលនឹងអរិយសច្ច ៤ ។*

ចប់អដ្ឋកថា អន្តសូត្រទី ๑

អដ្ឋកថា

ទុក្ខសូត្រទី ២

[៦] *គប្បីជ្រាបវិនិច្ឆ័យក្នុង* **ទុក្ខសូត្រទី ២** *ដូចតទៅនេះ ៖*

សូម្បីទុក្ខសូត្រទី ២ ព្រះមានព្រះភាគ ក៏ត្រាស់ទុកតាមអធ្យាស្រ័យរបស់វេនេយ្យសត្វដែលនឹងត្រាស់ដឹង ដោយពាក្យថា **ទុក្ខ** *ដោយទ្រង់ប្រកប ខន្ធ ៥ ចូលនឹងអរិយសច្ច ៤ ។*

ចប់អដ្ឋកថា ទុក្ខសូត្រទី ២

អ ដ្ឋ ក ថា

សក្កាយសូត្រទី ៣

[១១] *សូម្បីសូត្រទី ៣ ក៏ដូចគ្នា គឺ ព្រះមានព្រះភាគត្រាស់ទុកតាមអធ្យាស្រ័យរបស់វេនេយ្យសត្វដែលនឹងត្រាស់ដឹងបាន ដោយពាក្យថា* ***សក្កាយោ*** *ដោយទ្រង់ប្រកបខន្ធ ៥ ចូលនឹងអរិយសច្ច ៤ ។*

ចប់អដ្ឋកថា សក្កាយសូត្រទី៣

អ ដ្ឋ ក ថា

បរិញ្ញេយ្យសុត្តទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង ***បរិញ្ញេយ្យសូត្រទី ៤*** *ដូចតទៅនេះ ៖*

[១៦] *បទថា* ***បរិញ្ញេយ្យេ*** *បានដល់ ធម៌ទាំងឡាយដែលគប្បីកំណត់ដឹង គឺ គប្បីឈានកន្លង ។*

បទថា ***បរិញ្ញំ*** *បានដល់ កំណត់ដឹងដោយការឈានកន្លង ។*

បទថា ***បរិញ្ញាតាវី*** *បានដល់ បុគ្គលដែលកំណត់ដឹងច្បាស់ឈានកន្លងហើយ ដោយបរិញ្ញានោះ ។*

[១៨] *ព្រះមានព្រះភាគទ្រង់សម្តែងដល់ព្រះនិព្វាន ដោយបទថា* ***វាគក្ខ-យោ*** *ជាដើម ។*

ចប់អដ្ឋកថា បរិញ្ញេយ្យសូត្រទី ៤

អ ដ្ឋ ក ថា

សមណសូត្រទី ៥

[២០] *មិនបានអធិប្បាយទុកដោយចំពោះ ដូចក្នុងសូត្រដទៃៗ ទេ តែអធិប្បាយរួមថា "ព្រះមានព្រះភាគត្រាស់សច្ចៈ ៤ ទុក ក្នុង ៤ សូត្រ រាប់តាំងពីសូត្រទី ៥ ដល់សូត្រទី ៨" ។*

ចប់អដ្ឋកថា សមណសូត្រទី ៥

ចប់អន្តរវគ្គទី ១

រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថា អន្តសូត្រ	២-អដ្ឋកថា ទុក្ខសូត្រ
៣-អដ្ឋកថា សក្កាយសូត្រ	៤-អដ្ឋកថា បរិញ្ញេយ្យសូត្រ
៥-អដ្ឋកថា សមណសូត្រ	

ធម្មកថិកវគ្គ

អ ដ្ឋ ក ថា

អវិជ្ជាសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ***អវិជ្ជាសូត្រទី ១*** *នៃធម្មកថិកវគ្គដូចតទៅនេះ ៖*

[๒๗] *បទថា* ***ឯត្តាវតា ច អវិជ្ជាគតោ ហោតិ*** *សេចក្តីថា ដោយហេតុដែលជាអ្នកប្រកបដោយអវិជ្ជា ព្រោះការមិនដឹងក្នុងសច្ចៈ ๔ នេះ កិត្តុ ទើបឈ្មោះថា ធ្លាក់នៅក្នុងអវិជ្ជា ។*

ចប់អដ្ឋកថា អវិជ្ជាសូត្រទី ๑

អ ដ្ឋ ក ថា

វិជ្ជាសូត្រទី ២

[**២៨**] *សូម្បីក្នុង* ***វិជ្ជាសូត្រទី ២*** *ក៏មានន័យដូចគ្នានេះឯង ។*

ចប់អដ្ឋកថា វិជ្ជាសូត្រទី ២

អ ដ្ឋ ក ថា

ធម្មកថិកសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង **ធម្មកថិកសូត្រទី ៣** *ដូចតទៅនេះ ៖*

[២៩] *ព្រះមានព្រះភាគត្រាស់ដល់ព្រះធម្មកថិក ដោយពាក្យឆ្លើយទី ១ , ត្រាស់ដល់សេក្ខភូមិ ដោយពាក្យឆ្លើយទី ២ , ត្រាស់ដល់អសេក្ខភូមិ ដោយពាក្យឆ្លើយទី ៣ ។ រួមសេចក្តីមក ព្រះមានព្រះភាគត្រាស់ភូមិ ២ អធិប្បាយព្រះធម្មកថិកឲ្យផ្សេងគ្នាដោយពាក្យសួរ ដែលភិក្ខុទូលសួរហើយ ។*

ចប់អដ្ឋកថា ធម្មកថិកសូត្រទី ៣

អ ដ្ឋ ក ថា

ធម្មកថិកសូត្រទី ៤

[៣០] ក្នុង **ធម្មកថិកសូត្រទី ៤** ព្រះមានព្រះភាគត្រាស់ការវិសជ្ជនា ពាក្យសួរទាំង ៣ ទុក ៣ ប្រការ ។

ចប់អដ្ឋកថា ធម្មកថិកសូត្រទី ៤

អ ដ្ឋ ក ថា

ពន្ធនសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង ***ពន្ធនសូត្រទី ៥*** *ដូចតទៅនេះ ៖*

[៣១] *បទថា* ***អតីរទស្សី*** *សេចក្តីថា វដ្ដៈ ព្រះមានព្រះភាគត្រាស់ហៅថា ឆ្នេរ បុថុជ្ជនមើលមិនឃើញឆ្នេរនោះ ។*

បទថា ***អបារទស្សី*** *សេចក្តីថា និព្វាន ព្រះមានព្រះភាគត្រាស់ហៅថា ត្រើយ បុថុជ្ជនមើលមិនឃើញត្រើយនោះ ។*

បទថា ***ពន្ធោ*** *សេចក្តីថា (បុថុជ្ជន) ជាអ្នកជាប់ចំណងដោយកិលេស ទើប* ***កើត ចាស់ ស្លាប់*** *និងចាកលោកនេះទៅកាន់លោកដទៃ (ទាំងជាប់ចំណង) ។*

ព្រះមានព្រះភាគ ត្រាស់វដ្ដទុក្ខ ទុកក្នុងសូត្រនេះឯង ។

ចប់អដ្ឋកថា ពន្ធនសូត្រទី ៥

អ ដ្ឋ ក ថា

បរិមុចចិត្តសូត្រទី ៦ ដល់ខ្ទបាទានសូត្រទី ៩

[៣៣] *សូត្រទាំងនោះ ងាយទាំងអស់នោះឯង ។*

អ ដ្ឋ ក ថា

សីលសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង ***សីលសូត្រទី ១០*** *ដូចតទៅនេះ ៖*

[៣៧] *ក្នុងបទថា* ***អនិច្ចតោ*** *ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

ឧបាទានក្ខន្ធ ៥ ភិក្ខុគប្បីធ្វើទុកក្នុងចិត្តថា មិនទៀង ដោយអាការ ដែលមានហើយត្រឡប់ជាមិនមាន (កើតហើយរលត់) គប្បីធ្វើទុកក្នុងចិត្តថា ជាទុក្ខ ដោយអាការដែលបៀតបៀន ញាំញី , គប្បីធ្វើទុកក្នុងចិត្តថា ជារោគ ព្រោះសេចក្តីថា ឈឺចាប់ , គប្បីធ្វើទុកក្នុងចិត្តថា ជាបូស ព្រោះសេចក្តីថា ស្អុយខាងក្នុង , គប្បីធ្វើទុកក្នុងចិត្តថា មុត (មុតដោយសរ) ព្រោះជាបច្ច័យ ដល់បូសទាំងនោះ ឬព្រោះមានន័យថា ជីក , គប្បីធ្វើទុកក្នុងចិត្តថា លំបាក ព្រោះអត្ថថាទុក្ខ , គប្បីធ្វើទុកក្នុងចិត្តថា ជាអ្នកបៀតបៀន ព្រោះអត្ថថា ជាបច្ច័យឲ្យកើតអាពាធ ដែលមានមហាភូតរូបដែលជាវិសភាគគ្នាជាសមុដ្ឋាន គប្បីធ្វើទុកក្នុងចិត្តថា ជារបស់ដទៃ ព្រោះអត្ថថា មិនមែនរបស់ខ្លួន , គប្បីធ្វើទុកក្នុងចិត្តថា ទ្រុឌ្រោម ព្រោះអត្ថថា គ្រាំគ្រា , គប្បីធ្វើទុកក្នុងចិត្តថា សូន្យ ព្រោះអត្ថថា សូន្យចាកសត្វ , គប្បីធ្វើទុកក្នុងចិត្តថា ជាអនត្តា ព្រោះ

មិនមានអត្តា ។

ក្នុងទីនេះ គប្បីជ្រាបសេចក្តីអធិប្បាយបន្ថែមយ៉ាងនេះថា ព្រះមាន-ព្រះភាគត្រាស់ដល់ការធ្វើទុកក្នុងចិត្តថា មិនទៀង ដោយពីរបទថា ***អនិច្ចតោ បលោកតោ*** *(មិនទៀង , បែកធ្លាយ) ត្រាស់ដល់ការធ្វើទុកក្នុងចិត្តថាជាអនត្តា ដោយពីរបទថា* ***សុញ្ញតោ អនត្តតោ*** *(សូន្យ , ជាអនត្តា) ត្រាស់ដល់ការធ្វើទុកក្នុងចិត្តថា ជាទុក្ខ ដោយបទដ៏សេស ។ បទដ៏សេសក្នុងព្រះសូត្រនេះមានអត្ថងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា **សីលសូត្រទី ๑๐**

អ ដ្ឋ ក ថា

សុតវាសូត្រទី ១១

[៤២] ក្នុង **សុតវាសូត្រទី ១១** ក៏ដូចគ្នា គឺ មានអត្ថាធិប្បាយនោះឯង ។ ប៉ុន្តែថា ក្នុងសូត្រទី ១០ ព្រះមានព្រះភាគត្រាស់ **ចារិសុទ្ធិសីល** ទុកដោយបទថា **សីលវតា** ។ ក្នុងសូត្រទី ១១ នេះ ត្រាស់កម្មដ្ឋានទុក ដោយបទថា **សុតវតា** នេះជាសេចក្តីដែលផ្សេងគ្នា ។

ចប់អដ្ឋកថា សុតវាសូត្រទី ១១

អ ដ្ឋ ក ថា

កប្បសូត្រទី ១២

[៤៥] *កប្បសូត្រទី ១២ (មានសេចក្តី) ដូចពាហុលោភទសូត្រនុ៎ះឯង ។*

ចប់អដ្ឋកថា កប្បសូត្រទី ១២

អ ដ្ឋ ក ថា

កប្បសូត្រទី ១៣

[๔๖] *កប្បសូត្រទី ១៣ (មានសេចក្តី) ដូចពាហុលោរាទសូត្រនុ៎ះឯង ។*

ចប់អដ្ឋកថា កប្បសូត្រទី ១៣

ចប់ធម្មកថិកវគ្គទី ២

រួមក្នុងវគ្គនេះមាន ១១ អដ្ឋកថា

๑-អដ្ឋកថា អវិជ្ជាសូត្រ
๒-អដ្ឋកថា វិជ្ជាសូត្រ
๓-អដ្ឋកថា ធម្មកថិកសូត្រទី ๑
๔-អដ្ឋកថា ធម្មកថិកសូត្រទី ๒
๕-អដ្ឋកថា ពន្ធនសូត្រ
๖-អដ្ឋកថា បរិមុខចិត្តសូត្រទី ๑
๗-អដ្ឋកថា បរិមុខចិត្តសូត្រទី ๒
๘-អដ្ឋកថា សីលសូត្រ
๙-អដ្ឋកថា សុត្វាសូត្រ
๑๐-អដ្ឋកថា កប្បសូត្រទី ๑
๑๑-អដ្ឋកថា កប្បសូត្រទី ๒

อวิชชาวัคคที่ ๓

อ ฏ ฐ ก ถา

สมุฏฐยธัมมสูตรที่ ๑

[๔๗-๖๐] ***อัฏฐกถาสูตรที่ ๑*** *ถัดสูตรที่ ๑๐ เบื้องหน้าแต่สมุฏฐย-ธัมมสูตร ในอาวิชชาวัคค มีอรรถกถาทั้งสิ้น ๆ ก็ในวัคคนี้ พระมาน-พระภาค ตรัสเทศนา ๔ ครั้งในสูตรทั้งหลาย สูตร (ตั้งแต่สูตรที่ ๑ ถึงสูตรที่ ๑๐) นั่นเทียว ๆ*

จบอวิชชาวัคคที่ ๓
ในวัคคนี้ มีอรรถกถา
๑๐ สูตรเท่านั้น ๆ

កក្កឡវគ្គទី ៤

អ ដ្ឋ ក ថា

កក្កឡសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ***កុក្កុឡសូត្រទី ១*** *នៃ* ***កុក្កុឡវគ្គ*** *ដូចតទៅនេះ ៖*

[៦១] *បទថា* ***កុក្កុឡំ*** *ប្រែថា ក្តៅ គឺ ឆេះដោយភ្លើង ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់លក្ខណៈរបស់ទុក្ខ ដែលមានសភាពក្តៅ ទុកដូចជាគំនរផេះ ។*

ក្នុងសូត្រដ៏សេស ព្រះមានព្រះភាគត្រាស់ចែកលក្ខណៈទាំងអស់នេះ មានអនិច្ចលក្ខណៈជាដើម ទុកតាមអធ្យាស្រ័យរបស់បុគ្គលនោះឯង ។

ចប់កក្កឡវគ្គទី ៤

นิทานวรรคที่ ๕

อัฏฐกถา

อัฏฐเทวตาสูตรที่ ๑

[๗๓] สูตรที่ ๑ พากยว่า **กึ อุปาทายา** ดังนี้เป็นต้น เพราะอาศัยอะไร ฯ

จบอัฏฐกถา อัฏฐเทวตาสูตรที่ ๑

អ ដ្ឋ ក ថា

ឯតំមមសុត្តនិ ២

[៧៩] ក្នុងសូត្រទី ២ ពាក្យថា **កិ អត្ថិនិវិស្ស** បានដល់ ព្រោះប្រកាន់អ្វី អធិប្បាយថា ធ្វើឲ្យជាបច្ច័យ ។

ចប់អដ្ឋកថា ឯតំមមសុត្តនិ ២

អ ដ្ឋ ក ថា

ឯសោអត្តសូត្រទី ៣

[៧៧] ក្នុងសូត្រទី ៣ ជាដើម ពាក្យថា **ទិដ្ឋិ** ជាដើម ព្រះមានព្រះ-
ភាគត្រាស់ តាមអធ្យាស្រ័យរបស់បុគ្គល ។

ចប់អដ្ឋកថា ឯសោអត្តសូត្រទី ៣

អដ្ឋកថា

អានន្ទសូត្រទី ១០

[៩១] *គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា* ***ឧបសង្កមិ*** *ក្នុងអានន្ទសូត្រទី ១០ ។ ព្រះអានន្ទត្ថេរឃើញពួកភិក្ខុដទៃ ក៏ញុំាងព្រះសាស្តាដើម្បីប្រទាននូវកម្មដ្ឋាន គឺ ខន្ធ ៥ ប្រកបហើយ ក៏សម្រេចព្រះអរហត្ត ទើបព្យាករណ៍ព្រះអរហត្តក្នុងសំណាក់ព្រះសាស្តា ទើបគិតថា សូម្បីយើងក៏នឹងញុំាងព្រះសាស្តាឲ្យត្រាស់ប្រទានកម្មដ្ឋាន គឺ ខន្ធ ៥ ប្រកបហើយ ក៏សម្រេចព្រះអរហត្ត នឹងព្យាករណ៍ព្រះអរហន្ត ដូច្នេះ ទើបចូលទៅគាល់ ។*

ឯព្រះសាស្តាសូម្បីទ្រង់មិនឃើញការលះកិលេសទាំងឡាយ ដែលមគ្គខាងលើបីគប្បីសម្ងាប់របស់ព្រះថេរៈ ក្នុងវេលាដែលព្រះអង្គទ្រង់មានព្រះជន្មនៅ ក៏ត្រាស់ប្រាប់ដោយព្រះតម្រិះថា តថាគតនឹងកំណត់មើលចិត្តរបស់ភិក្ខុនេះ ។ ក៏ចិត្តរបស់ព្រះថេរៈនោះបានស្តាប់ហើយ មនសិការព្រះ-កម្មដ្ឋានលើកទីមួយ ឬលើកទីពីរ តែប្រព្រឹត្តទៅដោយគិតថា វេលានេះជាវេលាឧបដ្ឋាកដល់ព្រះសម្ពុទ្ធ ។ ព្រះអានន្ទត្ថេរនោះ មានធម៌ជាគ្រឿង

អប់រំនូវវិមុត្តិ ហើយញុំាងចិត្តរបស់ខ្លួនឲ្យរីករាយ ជាបុគ្គលប្រកបរឿយៗ

ក្នុងព្រះកម្មដ្ឋាន នឹងបានសម្រេច ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា អានន្ទសូត្រទី ១០

ចប់ឥដ្ឋិវគ្គទី ៥

រួមក្នុងវគ្គនេះមាន ០៤ អដ្ឋកថា

១-អដ្ឋកថា អដ្ឋត្តិកសូត្រ ២-អដ្ឋកថា ឱតំមសូត្រ

៣-អដ្ឋកថា ឱសោអត្តសូត្រទី ១ ១០-អដ្ឋកថា អានន្ទសូត្រ

ចុឡ្លបណ្ណាសក: រួមមាន ៥ វគ្គ

គឺ

អត្តវគ្គ . ធម្មកថិកវគ្គ . អវិជ្ជាវគ្គ . កុក្កុឡវគ្គ . ឥដ្ឋិវគ្គ

ចប់បណ្ណាសក:ដែលមានក្នុងខន្ធសំយុត្ត ៣ បណ្ណាសក:

រាធសំយុត្ត

បឋមវគ្គ

អ ដ្ឋ ក ថា

មារសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ***មារសូត្រទី*** *១ ដូចតទៅនេះ ៖*

[៨៣] *បទថា* ***មារោ វា អស្ស*** *សេចក្តីថា សេចក្តីស្ងាប់គប្បីមាន ។*

បទថា ***មារោតោ វា*** *សេចក្តីថា ឬសត្វអ្នកត្រូវសម្លាប់ (គប្បីមាន) ។*

បទថា ***យោ វា បន មិយ្យតិ*** *សេចក្តីថា ឬថា អ្នកណាស្លាប់ ។*

បទថា ***និព្វិទត្ថំ*** *បានដល់ ដើម្បីនិព្វទាញ្ញាណ ។*

បទថា ***និព្វានត្ថា*** *សេចក្តីថា ឈ្មោះថា ផលវិមុត្តិនេះ មានអនុបាទា-និព្វានជាផល អធិប្បាយថា ដើម្បីអនុបាទានិព្វាន ។*

បទថា ***អច្ចសរា*** *សេចក្តីថា អ្នកប្រព្រឹត្តកន្លង គឺ សូរហួសបញ្ញាហើយ ។*

បទថា ***និព្វានោគធំ*** *សេចក្តីថា តាំងនៅក្នុងនិព្វាន អធិប្បាយថា*

ឈ្មោះថា មគ្គព្រហ្មចរិយៈរមែងនាំចូលទៅកាន់និព្វាន មិនកន្ទងអំពីនិព្វានឡើយ ។

បទថា **និព្វានបរិយោសានំ** សេចក្តីថា និព្វានជាទីបំផុត គឺ ជាផលសម្រេច បានដល់ ជាទីបញ្ចប់នៃមគ្គព្រហ្មចរិយៈនោះ ។

ចប់អដ្ឋកថា មារសូត្រទី ១

អ ដ្ឋ ក ថា

សត្តសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង ***សត្តសូត្រទី ២*** *ដូចតទៅនេះ ៖*

[៩៤] *បទថា* ***សត្តោ*** *ជាពាក្យសួរដល់បុគ្គល ។*

បទថា ***តត្រ សត្តោ តត្រ វិសត្តោ*** *សេចក្តីថា អ្នកជាប់ គឺ អ្នកជាប់ជំពាក់នៅក្នុងឧបាទានក្ខន្ធនោះ ។*

បទថា ***បំស្វាគារកេហិ*** *ប្រែថា កូនផ្ទះដែលធ្វើដោយអាចម៍ជី ។*

បទថា ***កេឡាយន្តិ*** *ប្រែថា លេង ។*

បទថា ***ធនាយន្តិ*** *ប្រែថា សម្គាល់កូនផ្ទះដែលធ្វើដោយអាចម៍ជីថា ដូចជាទ្រព្យ ។*

បទថា ***មមាយន្តិ*** *បានដល់ ធ្វើការប្រកាន់ថា នេះរបស់យើង នេះរបស់យើង គឺ មិនព្រមសូម្បីឲ្យអ្នកដទៃប៉ះពាល់ ។*

បទថា ***វិកីឡនកំ ករោន្តិ*** *សេចក្តីថា ក្មេងប្រុស ឬក្មេងស្រីទាំងនោះ គិតថា ការលេងរួចហើយ ទើបឈូសចោលធ្វើឲ្យលេងមិនកើត ។*

ចប់អដ្ឋកថា សត្តសូត្រទី ២

អ ដ្ឋ ក ថា

ភវនេត្តិសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ***ភវនេត្តិសូត្រទី ៣*** *ដូចតទៅនេះ ៖*

[៩៥] *បទថា* ***ភវនេត្តិ*** *បានដល់ តណ្ហា ដូចខ្សែចង់សត្វទុកក្នុងភព ។*

ចប់អដ្ឋកថា ភវនេត្តិសូត្រទី ៣

អ ដ្ឋ ក ថា

បរិញ្ញេយ្យសុត្តទី ៤

[៩៦] *សូត្រទី ៤ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា បរិញ្ញេយ្យសូត្រទី ៤

អ ដ្ឋ ក ថា

បឋមសមណព្រាហ្មណសូត្រទី ៥

[៨៧] *ព្រះមានព្រះភាគត្រាស់សច្ចៈ ៤ ទុកក្នុង ៤ សូត្រ មាន បឋមសមណព្រាហ្មណសូត្រទី ៥ ជាដើម (និង) ត្រាស់ការលះបង់កិលេស ទុកក្នុង ២ សូត្រ នោះឯង ។*

ចប់អដ្ឋកថា បឋមសមណព្រាហ្មណសូត្រទី ៥

ចប់បឋមវគ្គទី ១

រួមក្នុងវគ្គនេះមាន ០៥ អដ្ឋកថា

១-អដ្ឋកថា មារសូត្រ ២-អដ្ឋកថា មារធម្មសូត្រ
៣-អដ្ឋកថា ភវនេត្តិសូត្រ ៤-អដ្ឋកថា បរិញ្ញេយ្យសូត្រ
៥-អដ្ឋកថា បឋមសមណព្រាហ្មណសូត្រជាដើម....

ទុតិយវគ្គ

អ ដ្ឋ ក ថា

មារសូត្រទី ១

[១០៤] ក្នុង **មារសូត្រទី ១** នៃ **ទុតិយវគ្គទី ២** ដោយពាក្យថា **មារ** ព្រះរាជត្តេរ រមែងទូលសួរដល់សេចក្តីស្ងាប់ ។ សេចក្តីថា ក៏ព្រោះឈ្មោះថា សេចក្តីស្ងាប់ដែលផុតចាកខន្ធ មានរូបជាដើមមិនមាន ។ ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ដល់ព្រះថេរៈ មានជាដើមថា " **ម្នាលវាធៈ រូបនេះឯងជាមារ** " ។

ចប់អដ្ឋកថា មារសូត្រទី ១

អ ដ្ឋ ក ថា

មារធម៌សូត្រទី ២

[១០៥] *ក្នុងសូត្រទី ២ ពាក្យថា* ***មារធម៌*** *បានដល់ មរណធម៌ ។*

អត្ថទាំងពួងគប្បីជ្រាបដោយឧបាយនេះ ដូច្នេះ ។

ចប់អដ្ឋកថា មារធម្មសូត្រទី ២

ចប់ទុតិយវគ្គទី ២

រួមក្នុងវគ្គនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា មារសូត្រ ២-អដ្ឋកថា មារធម្មសូត្រ

អ ដ្ឋ ក ថា

អាយាចនវគ្គទី ៣

[១១៦] *សេចក្តីតទៅនេះ ងាយទាំងអស់នោះឯង ។ ពិតណាស់ ព្រះរាជត្តៃរនេះ ឈ្មោះថា ជាព្រះថេរៈដែលឈ្លាសវៃ ។ ព្រោះទ្រង់ទតឃើញ ព្រះថេរៈនេះ ហេតុការណ៍ដ៏ល្អិត ទើបប្រោកជដល់ព្រះមានព្រះភាគ ។ ដោយ ហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងធម៌ជូនព្រះរាជៈនោះ ដោយ នយផ្សេងៗ ។ ដូច្នេះ ក្នុងរាជសំយុត្តនេះ ២ វគ្គខាងដើម ព្រះមានព្រះភាគ ទ្រង់សម្តែងទុកដោយអំណាចការសួរ ។*

វគ្គទី ៣ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចការទូលសូម ។

ចប់អដ្ឋកថា អាយាចនវគ្គទី ៣

ចប់អាយាចនវគ្គទី ៣

រួមក្នុងវគ្គនេះមាន ០១ អដ្ឋកថា

១-អដ្ឋកថា គឺ អាយាចនវគ្គទី៣

ឧបនិសិន្នវគ្គទី ៤

អ ដ្ឋ ក ថា

វគ្គទី ៤

[១២៨] *ព្រះមានព្រះភាគត្រាស់ដោយអំណាចឧបនិសិន្នកថា ។ តែថា ភាគសំយុត្តនេះសូម្បីទាំងអស់ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ធ្វើដោយអំណាចធម៌ជាគ្រឿងអប់រំវិមុត្តិដល់ព្រះថេរៈ ។*

ចប់អដ្ឋកថា ឧបនិសិន្នវគ្គទី ៤

ចប់ឧបនិសិន្នវគ្គទី ៤

រួមក្នុងវគ្គនេះមាន ០១ អដ្ឋកថា

១-អដ្ឋកថា គឺ ឧបនិសិន្នវគ្គទី៤

ទិដ្ឋិសំយុត្ត

សោតាបត្តិវគ្គទី ១

អ ដ្ឋ ក ថា

ទារុសូត្រទី ១

[១៤៤] *គប្បីជ្រាបវិនិច្ឆ័យក្នុង* ***ទិដ្ឋិសំយុត្ត*** *ដូចតទៅនេះ ៖*

ក្នុងបទថា ***ន ហិតា ហាយន្តិ*** *ជាដើម មានអធិប្បាយថា បានឮថា ជនទាំងនោះ មានការឃើញយ៉ាងនេះថា ខ្យល់ដែលបក់បំបាក់មែកឈើជាដើម មិនមែនខ្យល់ (ដែលពិត) នោះ ឈ្មោះថា ជាលេស (អាការ) របស់ខ្យល់ ចំណែកខ្យល់ ក៏តាំងនៅមាំដូចសសរគោល និងដូចកំពូលភ្នំ ។*

ម្យ៉ាងទៀត ទឹកស៊ីងដែលហូរនាំស្មៅ និងឈើជាដើម នោះមិនមែនទឹកហូរ ជាលេស (អាការ) របស់ទឹក ចំណែកទឹក ក៏តាំងនៅមាំដូចសសរ-គោល និងដូចកំពូលភ្នំ ។

ម្យ៉ាងទៀត ស្ត្រីមានគក៌ពួកណា ដែលនាំគ្នាពោលថា សម្រាលកូនស្ត្រីទាំងនោះ សូម្បីនឹងមានផ្ទៃសម្រាលហើយក៏ពិត តែក៏មិនឈ្មោះថា គក៌ (របស់ស្រីទាំងនោះ) នឹងសម្រាលមក នោះឈ្មោះថា ជាលេស (អាការ) របស់គក៌ ចំណែកគក៌ ក៏តាំងនៅមាំដូចសសរគោល និងដូចកំពូលភ្នំ ។

ម្យ៉ាងទៀត ព្រះចន្ទ និងព្រះអាទិត្យ រះ ឬលិច ក៏មិនឈ្មោះថា រះ (ពិត) មិនឈ្មោះថា លិច (ពិត) នោះឈ្មោះថា ជាលេស (អាការ) របស់ព្រះចន្ទ និងព្រះអាទិត្យ , ចំណែកព្រះចន្ទ និងព្រះអាទិត្យ ក៏តាំងនៅមាំដូចសសរគោល និងដូចកំពូលភ្នំ ។

ចប់អដ្ឋកថា ឯតសូត្រទី ១

អ ដ្ឋ ក ថា

ឯតមត្ថសូត្រទី ២ ដល់ នោចមេសិយាសូត្រទី ៤

[១៨៩] ក្នុងបទថា **ទិដ្ឋំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖ អារម្មណ៍ដែលឃើញបាន (**ទិដ្ឋំ**) បានដល់ រូបាយតនៈ , អារម្មណ៍ដែលបានឮ (**សុតំ**) បានដល់ សទ្ទាយតនៈ , អារម្មណ៍ដែលបានជ្រាប (**មុតំ**) បានដល់ គន្ធាយតនៈ រសាយតនៈ (និង) ផោដ្ឋព្វាយតនៈ ។ ក៏គន្ធាយតនៈ រសាយតនៈ (និង) ផោដ្ឋព្វាយតនៈ នុ៎ះហៅថា អារម្មណ៍ដែលបានជ្រាប (**មុតំ**) ព្រោះត្រូវ (ឲ្យ) មកដល់ (បសាទរូប) មុន ទើបនឹងទទួលបាន ។ អាយតនៈ ៧ ដ៏សេស ឈ្មោះថា **វិញ្ញាតំ** ។

បទថា **បត្តំ** បានដល់ អារម្មណ៍ដែលស្វែងរក ឬមិនស្វែងរកក៏ដោយ (តែ) បានប្រសព្វ ។

បទថា **បរិយេសិតំ** បានដល់ អារម្មណ៍ដែលស្វែងរកហើយ ដែលមកជួបប្រសព្វ ឬមិនជួបប្រសព្វក៏ដោយ ។

បទថា **អនុវិចរិតំ មនសា** បានដល់ អារម្មណ៍ដែលចិត្តតាមពិចារណាហើយ ។

ពិតណាស់ អារម្មណ៍ក្នុងលោក ស្វែងរកហើយ ទើបជួបក៏មាន ស្វែងរកហើយតែមិនជួបក៏មាន មិនបានស្វែងរកតែជួបក៏មាន មិនបានស្វែងរកហើយមិនបានជួបក៏មាន ។

ម្យ៉ាងទៀត អារម្មណ៍ដែលស្វែងរកហើយជួបខ្លះ ដែលមិនបានស្វែងរកតែជួបខ្លះ ឈ្មោះថា ***បត្ត*** *ព្រោះដោយអត្ថថា ជួបហើយ អារម្មណ៍ដែលស្វែងរកហើយតែមិនជួប ឈ្មោះថា* ***បរិយេសិត*** *(អារម្មណ៍ដែលស្វែងរកហើយ) អារម្មណ៍ដែលមិនបានស្វែងរកមិនបានជួប ឈ្មោះថា* ***មនសានុចរិតំ*** *(តាមពិចារណាដោយចិត្ត) ឬថា អារម្មណ៍ទាំងអស់នេះ ឈ្មោះថា តាមពិចារណាដោយចិត្តនោះឯង ។*

ចប់អដ្ឋកថាសូត្រទី ២ ដល់ សូត្រទី ៤

អ ដ្ឋ ក ថា

នត្ថិទិន្នសុត្តាទិ ៥

[១៥២] ក្នុងបទថា **នត្ថិ ទិន្នំ** ជាដើម មានអធិប្បាយដូចតទៅនេះ ៖

ដោយបទថា **នត្ថិ ទិន្នំ** បុគ្គលដែលជាមិច្ឆាទិដ្ឋិទាំងឡាយ ពោលថា ទានដែលឲ្យហើយមិនមានផល ។

ការបូជាធំ ហៅថា **យិដ្ឋៈ** ។ ក្នុងបទថា **ហុតំ** ព្រះមានព្រះភាគទ្រង់បំណងយកលាភសក្ការៈច្រើន ។ បុគ្គលជាមិច្ឆាទិដ្ឋិទាំងឡាយ បដិសេធបុញ្ញកម្មទាំងពីរយ៉ាងនោះ ដោយសំដៅយកថា មិនមានផលឡើយ ។

បទថា **សុកតទុក្កដានំ** ជានផល់ នៃកម្មដែលធ្វើល្អ និងធ្វើអាក្រក់ អធិប្បាយថា នៃកុសលកម្ម និងអកុសលកម្មទាំងឡាយ ។

បទថា **ផលំ វិបាកោ** សេចក្តីថា វត្ថុណាដែលហៅថា ផល ឬវិបាក បុគ្គលដែលជាមិច្ឆាទិដ្ឋិ រមែងពោលវត្ថុនោះថា មិនមាន ។

បទថា **នត្ថិ អយំ លោកោ** សេចក្តីថា លោកនេះសម្រាប់អ្នកនៅក្នុងបរលោក មិនមាន ។

បទថា **បរលោកោ** សេចក្តីថា លោកដទៃ សម្រាប់អ្នកដែលនៅក្នុង

លោកនេះ ក៏មិនមាន ។ ឧច្ឆេទវាទីបុគ្គល រមែងសម្តែងថា សព្វសត្វរមែងដាច់សូន្យ ក្នុងលោកនោះៗ ឯង ។

ឧច្ឆេទវាទីបុគ្គលពោលថា **នត្ថិ មាតា នត្ថិ បិតា** (មាតាមិនមាន បិតាមិនមាន) ដូច្នេះ ព្រោះ (គេប្រកាន់ថា) មិនមានផល ការបដិបត្តិត្រូវនិងការបដិបត្តិខុសក្នុងមាតាបិតាទាំងនោះ ។

ឧច្ឆេទវាទីបុគ្គលពោលថា **នត្ថិ សត្តា ឱបបាតិកា** (សត្វទាំងឡាយជាឱបបាតិក:មិនមាន) ដូច្នេះ ព្រោះជឿថា ឈ្មោះថា សត្វដែលចុតិហើយនិងឧប្បត្តិទៀត (ទៀត) មិនមាន ។

បទថា **ចាតុម្មហាភូតិកោ** សេចក្តីថា កើតមកពីមហាភូតរូប ៤ ។

បទថា **បថវី បថវីកាយំ** បានដល់ បឋវីធាតុខាងក្នុង (ទៅជា) បឋវីធាតុខាងក្រៅ ។

បទថា **អនុបេតិ** ប្រែថា ចូលដល់ ។ បទថា **អនុបគច្ឆតិ** ជាវេវចន:របស់បទថា **អនុបេតិ** នោះឯង ។ មានន័យថា ជ្រាបចូលទៅ ដូច្នេះខ្លះ ។

ដោយបទសូម្បីទាំងពីរ បុគ្គលជាមិច្ឆាទិដ្ឋិ រមែងសម្តែងថា ចូលដល់ គឺ ចូលទៅដល់ ។ ក្នុងធាតុដ៏សេស មានអាចោជាដើម ក៏មានន័យដូចគ្នានេះឯង ។

បទថា **ឥន្ទ្រិយានិ** សេចក្តីថា ឥន្ទ្រិយទាំង៦ឲ្យាយមានចិត្តជាទី ៦ រមែង អណ្តែតទៅកាន់អាកាស ។

បទថា **អាសន្ទិបញ្ចមា** សេចក្តីថា (បុរស ៤ នាក់) និងទាំងគ្រែដែល (បុគ្គលស្ទាប់) ដេក ជាទី ៥ ។ អធិប្បាយថា គ្រែ និងបុរស ៤ នាក់ ដែលឈរសែងគ្រែជើង ៤ ។

បទថា **យាវ អាឡាហនា** ប្រែថា រហូតដល់ព្រៃជាទីចោលសាកសព ។

បទថា **បទានិ** សេចក្តីថា ស្នាមជើង គឺ គុណ សេចក្តីល្អ (និងសេចក្តីអាក្រក់) ដែលប្រព្រឹត្តទៅ ដោយមានជាដើមថា បុគ្គលនេះជាអ្នកមានសីលល្អយ៉ាងនេះ បុគ្គលនេះ ជាអ្នកទ្រុស្តសីលយ៉ាងនេះ ។

ម្យ៉ាងទៀត ភាគកាយនុ៎ះឯង លោកបំណងថា ស្នាមជើងក្នុងទីនេះ ។

បទថា **កាបោតកានិ** ប្រែថា មានពណ៌ដូចសត្វព្រាប អធិប្បាយថា មានពណ៌ដូចស្មាបព្រាប ។

បទថា **កស្សន្តា** គឺ **កស្មន្តា** (ប្រែថា មានផេះជាទីបំផុត) ម្យ៉ាងទៀត **កស្មន្តា** នេះឯង គឺជាបាលី (ដើម) ។

បទថា **អាហុតិយោ** សេចក្តីថា ទានដែលបុគ្គលឲ្យហើយ ចែកប្រកេទជារបស់ទទួលភ្ងៀវ និងគ្រឿងសក្ការៈជាដើម ទាំងអស់សុទ្ធតែមានផេះជាទី

បំផុតនោះឯង មិនមានផលក្រៃលែងជាងនោះទេ ។

បទថា ***ទត្តុប្បញ្ញត្តមិទំ*** *គឺ ទាន ពួកបុគ្គលល្ងង់បញ្ញត្តិទុក ។ មានពាក្យអធិប្បាយដូច្នេះថា ពួកមិច្ឆាទិដ្ឋិសម្តែងថា ទាននេះ ពួកបុគ្គលល្ងង់ គឺបុគ្គលមិនដឹងបញ្ញត្តិទុក មិនមែនបុគ្គលឆ្លាតបញ្ញត្តិទុកទេ បុគ្គលល្ងង់ឲ្យ (ទាន) បុគ្គលឆ្លាតទទួល (ទាន) ។*

ចប់អដ្ឋកថា ឧត្តិទិន្នសូត្រទី ៥

អ ដ្ឋ ក ថា

##ករោតោសូត្រទី ៦[១]

[១៥៤] *បទថា* ***ករតោ***[១] *គឺ ធ្វើដោយដៃរបស់ខ្លួនឯង ។*

បទថា ***ការយតោ*** *គឺ ឲ្យគេធ្វើតាមពាក្យបង្គាប់ (ប្រើឲ្យធ្វើ) ។*

បទថា ***ឆិន្ទតោ*** *គឺ កាត់អវយវៈទាំងឡាយ មានដៃជាដើម របស់បុគ្គលដទៃ ។*

បទថា ***ឆេទាបយតោ*** *គឺ បៀតបៀនដោយអាជ្ញា ។*

បទថា ***សោចតោ*** *សេចក្ដីថា ធ្វើសេចក្ដីសោកដល់បុគ្គលដទៃដោយខ្លួនឯងក្ដី ប្រើឲ្យអ្នកដទៃធ្វើក្ដី ដោយទុច្ចរិតកម្ម មានលួចរបស់បុគ្គលដទៃជាដើម ។*

បទថា ***កិលមតោ*** *សេចក្ដីថា ធ្វើខ្លួនឯងឲ្យលំបាកក្ដី ធ្វើអ្នកដទៃឲ្យលំបាកក្ដី ដោយការបង្អត់អាហារ និងការបង្ខាំងក្នុងគុកជាដើម ។*

បទថា ***ផន្ទតោ ផន្ទាបយតោ*** *សេចក្ដីថា ក្នុងវេលាបៀតបៀនបុគ្គលដទៃដែលក្ដៅក្រហាយហើយ ឈ្មោះថា ទាំងធ្វើខ្លួនឯងឲ្យក្ដៅក្រហាយ ទាំងធ្វើឲ្យបុគ្គលដទៃសូម្បីនោះក្ដៅក្រហាយផង ។*

---

១ បាលីជា ករតោ ។

បទថា **បាណមតិបាតាបយតោ** សេចក្តីថា សម្រាប់សត្វខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃសម្រាប់ក្តី ។

ក្នុងគ្រប់ៗ បទ ក៏គប្បីជ្រាបនយ ដោយអំណាចហេតុនៃការធ្វើយ៉ាងនេះឯង ។

បទថា **សន្តិ** បានដល់ ទី.តរបស់ផ្ទះ ។

បទថា **និល្លោបំ** បានដល់ ប្លន់អ្នកស្រុក ។

បទថា **ឯកាគារិកំ** បានដល់ ប្លន់យកទ្រព្យតែផ្ទះមួយ ។

បទថា **បរិបន្ថេ** បានដល់ ចាំស្ទាក់ផ្លូវ ដើម្បីវាយដណ្តើមអ្នកដែលដើរទៅ ដើរមក ។

ដោយបទថា **ករតោ ន ករិយតិ បាបំ** អកិរិយវាទីបុគ្គលទាំងឡាយរមែងសម្តែងថា កាលបុគ្គលសូម្បីធ្វើហើយ ដោយសេចក្តីសម្គាល់ថា យើងធ្វើបាបណាមួយ បាបក៏មិនមែនជាការធ្វើ បាបមិនមាន ប៉ុន្តែថា សត្វទាំងឡាយមានសេចក្តីសម្គាល់យ៉ាងនេះថា យើងធ្វើ ។

បទថា **ខុរបរិយន្តេ ន** សេចក្តីថា ដោយមុតកាំបិតកោរ ឬដោយចុង (ដែលមុត) ដូចមុតកាំបិតកោរ ។

បទថា **ឯកំ មំសខលំ** បានដល់ គំនរនៃសាច់តែមួយ ។

បទថា **បុញ្ញំ** ជាវេវចន:នៃបទថា **មំសខលំ** នោះឯង ។

បទថា **តតោនិទានំ** បានដល់ មានការធ្វើឲ្យជាលាន‌សាច់តែមួយជា‌ហេតុ ។

បទថា **ទក្ខិណំ** សេចក្តីថា មនុស្សនៅត្រើយខាង‌ស្តាំ ជាបុគ្គលយោ-យៅ ព្រះមានព្រះភាគទ្រង់សំដៅយកបុគ្គលទាំងនោះ ទើបត្រាស់ពាក្យថា **ហនន្តោ** ជាដើម ។ មនុស្សនៅត្រើយខាងឆ្វេង ជាអ្នកមានសទ្ធាជ្រះថ្លា ជា‌ពុទ្ធមាមក: ធម្មមាមក: សង្ឃមាមក: ព្រះមានព្រះភាគ ទ្រង់សំដៅយក‌បុគ្គលទាំងនោះ ទើបត្រាស់ពាក្យថា **ទទន្តោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យជន្តោ** បានដល់ ធ្វើការបូជាធំ ។

បទថា **ទមេន** គឺ ដោយការទូន្មានឥន្ទ្រិយ បានដល់ ដោយឧបោ-សថកម្ម ។

បទថា **សំយមេន** គឺ ដោយការរក្សាសីល ។

បទថា **សច្ចវជ្ជេន** គឺ ដោយការពោលពាក្យសច្ចៈ ។

បទថា **អាគមោ** ប្រែថា ការមក អធិប្បាយថា ការប្រព្រឹត្តទៅ ។

អកិរិយវាទីបុគ្គល បដិសេធការធ្វើបុណ្យ និងបាបដោយសព្វគ្រប់ ។

ចប់អដ្ឋកថា កកោតោសូត្រទី ៦

អ ដ្ឋ ក ថា

ហេតុសូត្រទី ៧

[១៥៦] បទថា **បច្ចយោ** ក្នុងបទនេះថា **នត្ថិ ហេតុ នត្ថិ បច្ចយោ** ជាវេវចនៈរបស់ហេតុនុ៎ះឯង ។

អហេតុកវាទីបុគ្គល នាំគ្នាបដិសេធបច្ច័យនៃសេចក្តីសៅហ្មង នៃសង្កិ-លេសធម៌ទាំងឡាយ មានកាយទុច្ចរិតជាដើម និងបច្ច័យនៃសេចក្តីបរិសុទ្ធិ នៃភោគធម៌ទាំងឡាយ មានកាយសុចរិតជាដើម ដោយបទទាំងពីរ (**នត្ថិ ហេតុ នត្ថិ បច្ចយោ**) ។

សត្វទាំងឡាយនេះ តាំងនៅក្នុងកម្លាំងរបស់ខ្លួនយ៉ាងណា ហើយទើបសម្រេចដល់ភាពជាទេវតាខ្លះ ជាមារខ្លះ ជាព្រហ្មខ្លះ សាវកពោធិញ្ញាណខ្លះ ព្រះសព្វញ្ញុតញ្ញាណខ្លះ អហេតុកវាទីបុគ្គលបដិសេធកម្លាំងនោះ ដោយបទថា **នត្ថិ ពលំ** ។

បទដទៃទាំងអស់ មានជាដើម គឺ **នត្ថិ វីរិយំ** ជាវេវចនៈរបស់គ្នានិងគ្នានោះឯង តែបទទាំងនេះចែកទុកផ្សេងគ្នា ក៏ព្រោះបដិសេធពាក្យនិយាយដែលប្រព្រឹត្តទៅយ៉ាងនេះថា ផលនេះគប្បីសម្រេចដោយកម្លាំងរបស់បុរស

ផលនេះគប្បីសម្រេចដោយសេចក្តីឧស្សាហ៍របស់បុរស ។

អហេតុកវាទីបុគ្គល សំដៅដល់សត្វទាំងឡាយមិនមានសល់ មានអូដ្ឋ គោ និងលាជាដើម ដោយបទថា **សព្ពេ សត្តា** ។

អហេតុកវាទីបុគ្គល ពោលថា **សព្ពេ បាណា** ដោយអំណាចសំដៅយក មានជាដើម គឺ សត្វមានឥន្ទ្រិយតែម្យ៉ាង ។

អហេតុកវាទីបុគ្គល ពោលថា **សព្ពេ ភូតា** សំដៅយកសត្វទាំងឡាយដែលកើតហើយក្នុងសំបកពង និងផ្ទៃ (ស្បូន) ។

អហេតុកវាទីបុគ្គល ពោលថា **សព្ពេ ជីវា** សំដៅយក ជីវៈទាំងឡាយមានស្រូវសាលី ស្រូវខ្យាយ និងស្រូវដំណើបជាដើម អធិប្បាយថា ក្នុងវត្ថុដែលមានជីវិតទាំងនោះ ជីវៈទាំងនោះដែលបានជីងថា ជាជីវៈ ព្រោះមានការដុះលូតលាស់ឡើងបាន ។

បទថា **អវសា អពលា អវីរិយា** សេចក្តីថា វត្ថុដែលមានជីវិតទាំងនោះ មិនមានអំណាច កម្លាំង ឬវីរិយៈនៃខ្លួនឯង ។

ក្នុងបទថា **និយតិសង្គតិភាវបរិណតា** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **និយតិ** បានដល់ ភាពជាអ្នកមានជោគល្អ និងជោគអាក្រក់ ។

បទថា **សង្គតិ** បានដល់ ការប្រព្រឹត្តទៅក្នុងអភិជាតិ (កំណើត) នោះៗ បណ្តាអភិជាតិ ៦ យ៉ាង ។

បទថា **ភាវោ** បានដល់ សភាវៈនុ៎ះឯង ។

វត្ថុដែលមានជីវិតទាំងឡាយ ប្រែប្រួលទៅ គឺ ដល់ភាវៈច្រើនប្រការ តាមសភាពនៃការមានជោគល្អ និងជោគអាក្រក់ និងសភាពនៃការប្រព្រឹត្តទៅ (ក្នុងអភិជាតិផ្សេងៗ) ។ ពិតណាស់ អហេតុកវាទីបុគ្គលសម្តែងថា បុគ្គលណានីមួយប្រព្រឹត្តទៅយ៉ាងណា បុគ្គលនោះក៏នឹងត្រូវប្រព្រឹត្តទៅយ៉ាងនោះឯង (តែ) បុគ្គលណានីមួយមិនប្រព្រឹត្តទៅយ៉ាងណា បុគ្គលនោះក៏នឹងមិនប្រព្រឹត្តទៅយ៉ាងនោះ ដោយពិត ។

ដោយបទថា **ឆស្សាភិជាតីសុ** អហេតុកវាទីបុគ្គលសម្តែងថា វត្ថុដែលមានជីវិតទាំងឡាយ មានជីវិតតាំងនៅ សោយសុខ និងទុក្ខនៅក្នុងអភិ-ជាតិ ៦ ប៉ុណ្ណោះ មិនមានកូមិសម្រាប់សោយសុខ និងទុក្ខជាដៃ ។

ចប់អដ្ឋកថា ហោតុសូត្រទី ៧

អ ដ្ឋ ក ថា

មហានិដ្ឋិសូត្រជាដើម ដល់សូត្រទី ១០

[១៥៨] បទថា **អកជា** គឺ (កាយទាំង ៧) មិនមានអ្នកណាសាង ។

បទថា **អកជវិធា** គឺ មិនមានអ្នកណាធ្វើការចាត់ចែង (កសាង) អធិប្បាយថា សូម្បីដែលអ្នកណាៗ ឲ្យធ្វើ ដោយប្រាប់ថា ចូរធ្វើយ៉ាងនេះ ក៏មិនមាន ។

បទថា **អនិម្មិតា** គឺ មិនមានអ្នកណានិម្មិតសូម្បីដោយឫទ្ធិ ។

បទថា **អនិម្មិតវិធា** គឺ ការចាត់ចែង មិនមានអ្នកណានិម្មិត ។ អធិប្បាយថា មិនមែនអ្នកណាៗ គួរនិម្មិតបាន ។ បាឋៈថា **អនិម្មិតញ្ញា** ដូច្នេះខ្លះ ។

បទថា **វញ្ឈា** គឺ មិនមានផល បានដល់ មិនឲ្យកើតផលអ្វីៗ ដូចសត្វចិញ្ចឹមដែលគ្មានកូន និងដើមត្នោតឈ្មោលជាដើម ។

បទថា **កូដដ្ឋា** សេចក្តីថា តាំងនៅដូចកំពូលភ្នំ (ព្រោះហេតុនោះ) ទើបឈ្មោះថា **កូដដ្ឋា** ។

បទថា **ឯសិកដ្ឋាយិដ្ឋិតា** តាំងនៅ តាំងនៅដូចជាសសរគោល ព្រោះហេតុនោះទើបឈ្មោះថា **ឯសិកដ្ឋាយិដ្ឋិតា** អធិប្បាយថា សសរគោលដែល

កប់ល្អហើយ តាំងមាំមិនញាប់ញ័រ យ៉ាងណា កាយក៏តាំងនៅដូច្នោះ ។

បទថា **ន ឥញ្ជន្តិ** សេចក្តីថា មិនញាប់ញ័រ តាំងនៅមាំដូចសសរគោល ដូច្នោះ ។

បទថា **ន វិចរិណាមន្តិ** សេចក្តីថា មិនលះបង់ប្រក្រតី ។

បទថា **ន អញ្ញមញ្ញំ ព្យាធេន្តិ** សេចក្តីថា មិនបៀតបៀនគ្នានិងគ្នា ។

បទថា **នាលំ** ប្រែថា មិនអាច ។

ក្នុងបទថា **បថវីកាយោ** ជាដើម មានអធិប្បាយថា បឋវីធុ៎ះឯង ឈ្មោះថា បឋវីកាយៈ (គំនរដី) ឬបឋវីសមូហៈ (ប្រជុំដី) ។

បទថា **សត្តន្នំ ត្វេវ កាយានំ** មានសេចក្តីថា សស្ត្រាដែលចាក់ចូលទៅក្នុងគំនរសណ្តែកបាយជាដើម រមែងចូលទៅក្នុងចន្លោះសណ្តែកបាយជាដើម យ៉ាងណា សស្ត្រាក៏ជ្រែកចូលទៅក្នុងចន្លោះ គឺ ផ្លូវ បានដល់ ផ្លូវដែលជាចន្លោះរបស់កាយទាំង ៧ ដូច្នោះ ។

ក្នុងការសម្ងាប់នោះ ពួកមិច្ឆាទិដ្ឋិសម្តែងថា នឹងមានត្រឹមតែការសម្លាប់តែម្យ៉ាងប៉ុណ្ណោះថា យើងផ្តាច់ជីវិតអ្នកនេះ (សម្ងាប់សត្វ) ។

មិច្ឆាទិដ្ឋិកបុគ្គល (អ្នកនិយមក្នុងលទ្ធិនេះ) នាំគ្នាសម្តែងការជឿបែបគ្មានប្រយោជន៍ (ដែលបានមក) ដោយហេតុត្រឹមតែការត្រិះរិះតែម្យ៉ាង (ដោយ

ប្រើគោលតក្កវិទ្យាតែម្យ៉ាង) ថា កំណើតធំ គឺ កំណើតដែលសំខាន់ មាន ១.៤០០.០០០ រួមជាមួយកំណើតដទៃទៀត ៦.៦០០ និងកម្ម ៥០០ ទៀត ដោយបទថា **យោនិបមុខសតសហស្សានិ** ។

សូម្បីក្នុងបទថា **បញ្ច ច កម្មានិ តីណិ ច កម្មានិ** (កម្ម ៥ និងកម្ម ៣) ជាដើម ក៏មានន័យដូចគ្នានេះឯង ។

ចំណែកអាចារ្យពួកខ្លះពោលថា មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយពោលដល់កម្ម ៥ ដោយអំណាចឥន្ទ្រិយ ៥ , ពោលដល់កម្ម ៣ ដោយអំណាចកាយកម្មជាដើម ។

ចំណែកក្នុងបទថា **កម្មេ ច អឌ្ឍកម្មេ ច** (កម្ម និងកន្ទុះកម្ម) នេះមានអធិប្បាយថា កាយកម្ម និងវចីកម្មរបស់ម្ចាស់លទ្ធិនោះ បានឈ្មោះថា **ជាកម្ម** មនោកម្ម បានឈ្មោះថា **ជាកម្មពាក់កណ្តាល** ។

មិច្ឆាទិដ្ឋិកបុគ្គលពោលថា បដិបទា មាន ៦២ ដោយបទថា **ទ្វដ្ឋិ-ប្បដិបទា** ។

បទថា **ទ្វដ្ឋន្តរកប្បា** សេចក្តីថា ក្នុងកប្បធំមួយ មានកប្បឈ្មោះថា អន្តរកប្ប (កប្បតូច) ៦៤ កប្ប ។

ប៉ុន្តែថា ម្ចាស់លទ្ធិនេះ មិនជឿនកប្បដទៃ ២ ទៀត (សំវដ្ដដ្ឋាយីកប្ប ១

វិវដ្ដដ្ឋាយីកប្ប ១) ទើបពោល យ៉ាងនេះ ។

មិច្ឆាទិដ្ឋិកបុគ្គលពោលដល់ អកិជាតិ (កំណើត) ៦ ទាំងនេះ គឺ កណ្ហាកិជាតិ ១ នីលាកិជាតិ ១ លោហិតាកិជាតិ ១ ហលិទ្ទាកិជាតិ ១ សុក្កាកិជាតិ ១ បរមសុក្កាកិជាតិ ១ ដោយបទថា **ឆឡាកិជាតិយោ** ។

មិច្ឆាទិដ្ឋិកបុគ្គលពោលថា បណ្ដាកំណើតទាំង ៦ នោះ ឱរម្ភិកកំណើត (ការកើតជានាយព្រានកែះ) សូករិកកំណើត (ការកើតជានាយព្រានជ្រូក) សាកុណិកកំណើត (ការកើតជានាយព្រានបក្សី) មាគវិកកំណើត (ការកើតជានាយព្រាណ៍ម្រឹគ) លុទ្ទកំណើត (ការកើតជានាយព្រាន) មច្ឆមាដក-កំណើត (ការកើតជាព្រានប្រមង់) ចោរកំណើត (ការកើតជាចោរ) ចោយោ-ជកំណើត (ការកើតជាពេជ្រឃាតសម្លាប់ចោរ) ពន្ធនាគារិកកំណើត (ការកើតមេគុក) ឬថា ការងារដែលតិចតួចជនៃយ៉ាងណាមួយ នេះឈ្មោះថា **កណ្ហាកិជាតិ** (កំណើតខ្មៅ) ។

កំណើតកិក្ខុ មិច្ឆាទិដ្ឋិកបុគ្គលពោលថា **នីលាកិជាតិ** (កំណើតខៀវ) បានឮថា កិក្ខុទាំងនោះជាក់បន្ទាទៅក្នុងបច្ច័យ ៤ ហើយទើបឆាន់ (អាហារ) និងកិក្ខុទាំងឡាយក៏ចិញ្ចឹមជីវិតដោយអាស្រ័យបន្ទា ក៏បាលីដូចពោលមកនេះ ជាបាលីរបស់កិក្ខុនោះឯង ។

ម្យ៉ាងទៀត គេពោលគ្នាថា អ្នកបួសទាំងឡាយ ដូចជានៅក្នុងព្រៃបន្ទា ទើបមានឈ្មោះយ៉ាងនេះ (**កណ្ហកវុត្តិកា**) ។

គេពោលថា ពួកនិគ្រន្ថដែល ប្រើសំពត់ផ្ទាំងតែមួយ ឈ្មោះថា **លោហិតាភិជាតិ** (កំណើតក្រហម) ដែលបានដឹងថា និគ្រន្ថទាំងនេះបរិសុទ្ធជាង ២ ពួកដំបូង ។

គេពោលថា សាវកបស់អចេលក:ដែលជាគ្រហស្ថ ស្បៀកសដណ្តប់ស ឈ្មោះថា **ហលិទ្ទាភិជាតិ** (កំណើតលឿង) និគ្រន្ថទាំងឡាយ ធ្វើពួកសាវកដែលជាគ្រហស្ថ ថ្វាយបច្ច័យបស់ខ្លួន ឲ្យមានភាពសំខាន់ជាងពួកនិគ្រន្ថផងគ្នា ដោយអាការយ៉ាងនេះ ។

គេពោលថា ពួកអាជីវកប្រុស ពួកអាជីវកស្រី នេះឈ្មោះថា **សុក្កាភិជាតិ** ដែលគេដឹងថា អាជីវកទាំងស្រី និងប្រុសទាំងនោះ បរិសុទ្ធជាង ៤ ពួកដំបូង ។

គេពោលថា ម្ចាស់លទ្ធិឈ្មោះ នន្ទ: វច្ឆ: សង្កិច្ច: និងមក្ខលិគោសាល ឈ្មោះថា **បរមសុក្កាភិជាតិ** ។ ដែលគេដឹងថា ម្ចាស់លទ្ធិទាំងនោះ បរិសុទ្ធិជាងពួកដទៃទាំងអស់ ។

មិច្ឆាទិដ្ឋិកបុគ្គលពោលថា **ភូមិ** (លំដាប់នៃការចម្រើនធំធាត់) របស់

បុគ្គលមាន ៨ កូមិទាំងនេះ គឺ មន្ទកូមិ ១ ទិឌ្ឍាកូមិ ១ វិមំសកកូមិ ១ ឧជុគតកូមិ ១ សេក្ខកូមិ ១ សមណកូមិ ១ ជាននកូមិ ១ បន្នកូមិ ១ ដោយបទថា **អដ្ឋ បុរិសកូមិយោ** ។

បណ្តាកូមិទាំង ៨ នោះ ប្រសូតិមកក្នុង (វេលា) ៧ ថ្ងៃ ផ្តើមតាំងពីថ្ងៃកើត សត្វទាំងឡាយរាប់ថានៅទន់ខ្ចី ល្ងង់ខ្ចៅ ព្រោះចេញមកពីទីចង្អៀត គេថា នេះឈ្មោះថា **មន្ទកូមិ** ។

ចំណែកសត្វពួកណាមកពីទុគ្គតិ សត្វទាំងនោះ ស្រែកយំរឿយៗ និងស្រែកយំខ្លាំងៗ , (ចំណែក) សត្វពួកណាមកពីសុគតិ សត្វទាំងនោះនឹកដល់សុគតិនោះហើយ ក៏សើចសប្បាយ នេះឈ្មោះថា **ទិឌ្ឍាកូមិ** ។

ការចាប់ដៃ ឬជើងរបស់មាតាបិតា (ឬ) ចាប់គ្រែ ឬតាំង ហើយដាក់ជើងចុះជាន់ផែនដី ឈ្មោះថា **វិមំសកកូមិ** ។

វេលាដែលអាចដើរបាន ឈ្មោះថា **ឧជុគតកូមិ** ។

រយៈពេលដែលសិក្សាសិល្បៈ ឈ្មោះថា **សេក្ខកូមិ** ។

វេលាដែលចេញចាកផ្ទះបួស ឈ្មោះថា **សមណកូមិ** ។

វេលាដែលចេះដឹង ព្រោះសេព (សិក្សាមកពី) អាចារ្យ ឈ្មោះថា **ជាននកូមិ** ។

គេពោលដល់សមណៈដែលមិនឆ្ងាតយ៉ាងនេះថា ក៏កិក្ខុជាអ្នកក្លាត់ (ចាកប្រយោជន៍) ហើយ (ព្រោះ) ព្រះជិនស្រីមិនត្រាស់អ្វីទុក នេះឈ្មោះថា **បន្ទកូមិ** ។

បទថា **ឯកូនបញ្ញាស អាជីវកសតេ** បានដល់ វិធីដំណើរជីវិត ៤.៩០០ ។

បទថា **បរិព្វាជកសតេ** បានដល់ ការបួសជាបរិព្វាជក ១០០ ។

បទថា **នាគវាសសតេ** បានដល់ នាគមណ្ឌល ១០០ ។

បទថា **វីសេ ឥន្ទ្រិយសតេ** បានដល់ ឥន្ទ្រិយ ២.០០០ ។

បទថា **តីសេ និរយេសតេ** បានដល់ នរក ៣.០០០ ។

មិច្ឆាទិដ្ឋិកបុគ្គលពោលសំដៅដល់ខ្នងដៃ និងខ្នងជើងជាដើម ដែលជាទីរោយធូលីចុះ ដោយបទថា **រជោជាតុយោ** ។

ពោលសំដៅដល់ អូដ្ឋ គោ លា ពពែ សត្វ ចិញ្ចឹម ម្រឹគ និងក្របី ដោយបទថា **សត្តសញ្ញិគព្ភា** ។

ពោលសំដៅដល់ ស្រូវសាលី ស្រូវដំណើប ស្រូវខ្លាយ ស្រូវឆែ ថ្ពៅ សួយ និងស្មៅគែលលក ដោយបទថា **អសញ្ញិគព្ភា** ។

ពោលសំដៅដល់ ដើមអំពៅ ដើមឫស្សី និងដើមអំពៅជាដើម ដែល

មានដើម (ថ្មី) ដុះឡើងត្រង់ថ្នាំង ដោយបទថា **និគ្គណ្ឋិគព្ភា** ។

បទថា **សត្ត ទិញ្ញា** បានដល់ ទេពចំនួនច្រើន ក៏មិច្ឆាទិដ្ឋិកបុគ្គលនោះ ហៅ (ទេពទាំងនោះ) ថាសត្វ ។ សូម្បីមនុស្សក៏មានចំនួនច្រើន គេក៏ហៅ (មនុស្សទាំងនោះ) ថាសត្វ ។

បទថា **សត្ត បិសាចា** បានដល់ បីសាចចំនួនច្រើន មិច្ឆាទិដ្ឋិកបុគ្គល ក៏ហៅ (បីសាចចំនួនច្រើនទាំងនោះ) ថាសត្វ ។

បទថា **សរា** បានដល់ ស្រះធំ គេពោលសំដៅដល់ ស្រះកណ្ណមុណ្ឌៈ ស្រះរថការៈ ស្រះអនោតាតៈ ស្រះសីហបបាតៈ ស្រះមណ្ឌាកិនី ស្រះមុចលិន្ទ និងស្រះកុណាលៈ ។

បទថា **បវុដា** បានដល់ អន្ទង់ ។

បទថា **បបាតា** បានដល់ ជ្រោះធំ ។

បទថា **បបាតសតានិ** បានដល់ ជ្រោះតូច ៧០០ ។

បទថា **សុបិនា** បានដល់ សុបិនធំ ៧ ។

បទថា **សុបិនសតានិ** បានដល់ សុបិនតូច ៧០០ ។

បទថា **មហាកប្បិនោ** បានដល់ មហាកប្បទាំងឡាយ

ក្នុងប្រការនេះ ម្ចាស់លទ្ធិនោះ មានការយើញដូច្នេះថា កាលបុគ្គល

យកចុងស្បូវជ្រលក់ទឹកពីស្រះធំ ១ ដោយ ១០០ ឆ្នាំ តែទឹក ១ តំណក់ ហើយធ្វើស្រះនោះឲ្យរីងអស់ ៧ ដង (យ៉ាងនេះ) ចាត់ជាមហាកប្ប ១ ។ ពាល និងបណ្ឌិត បណ្តាយមហាកប្បបែបនេះ អស់ទៅបាន ៨.៤០០.០០០ មហាកប្ប ក៏នឹងធ្វើទីបំផុតទុក្ខបាន ។

គេជឿថា ក្នុងរយៈវេលាចន្ទោះនោះ សូម្បីបណ្ឌិតក៏មិនអាចនឹងបរិសុទ្ធិបាន ទាំងជនពាលក៏មិនកន្ងងហួសអំពីនោះទៅបាន ។

បទថា **សីលេន វា** បានដល់ ដោយសីលរបស់អចេលកៈ ឬដោយសីលយ៉ាងដទៃប្រភេទណាមួយ សូម្បីដោយវត្តក៏ដូច្នោះដូចគ្នា ។

បទថា **តវេន** សេចក្តីថា អ្នកណាគិតថា យើងជាបណ្ឌិត ហើយបរិសុទ្ធិក្នុងរយៈវេលាចន្ទោះ (មហាកប្បទាំងនោះ) អ្នកនោះឈ្មោះថា ធ្វើកម្មដែលនៅមិនទាន់ទុំជោរ ឲ្យទុំជោរ ដោយការបំពេញតបៈ ។ អ្នកណាគិតថា គេជាពាលដូច្នេះហើយ កន្ងងហួសវេលាកំណត់ ដូចពោលហើយ អ្នកនោះឈ្មោះថា បានប្រសព្វកម្មដែលនៅមិនទាន់ទុំជោរ ហើយធ្វើឲ្យដល់នូវទីបំផុតទៅបាន ។

បទថា **ហេវំ នត្ថិ** គឺ **ឯវំ នត្ថិ** ។ ក៏កម្មទាំងពីរយ៉ាងនោះ ម្ចាស់លទ្ធិសម្តែងថា នរណាៗ មិនអាចនឹងធ្វើបាន ។

បទថា **នោណមិតេ** ប្រែថា ដូចជាវាល់ដោយនាឡិ ។

បទថា **សុខទុក្ខេ** គឺ **សុខទុក្ខំ** (ប្រែថា សុខ និងទុក្ខ) ។

បទថា **បរិយន្តកតេ** គឺ (សង្សារវដ្ដ) ត្រូវធ្វើឲ្យមានទីបំផុតបានតាមវេលាមានកំណត់ដូចពោលហើយ ។

បទថា **នត្ថិ ហាយនវឌ្ឍនេ** គឺ មិនមានការវិនាស និងចម្រើន អធិប្បាយថា សង្សារវដ្ដរបស់បណ្ឌិតក៏មិនវិនាស (ដល់ទីបំផុត) របស់ជនពាលក៏មិនចម្រើន (លុតលាស់) ។

បទថា **ឧភំសាវកំសេ** នេះ ជាវេវចនៈរបស់សេចក្តីវិនាស និងសេចក្តីចម្រើនដូចគ្នា ។

ឥឡូវនេះ កាលនឹងឲ្យអត្ថនោះសម្រេចដោយឧបមា ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **សេយ្យថាបិ នាម** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សុត្តគុឡេ** បានដល់ ជុំអំបោះដែលខារទុកកំពុងរលាចេញទៅនុ៎ះឯង ។

ដោយបទថា **បលេតិ** ម្ចាស់លទ្ធិសម្តែងថា ជុំអំបោះដែលជាក់ (ត្រង់កន្លែងមួយ) ទុកលើក្តាំ ឬលើចុងឈើ ហើយត្រវែងទៅ នឹងរលាទៅតាមប្រវែងរបស់អំបោះ កាលអំបោះអស់ហើយ ក៏នឹងឈប់ក្នុងទីនោះឯង មិន

រលា.តទៅទៀត យ៉ាងណា ពាល និងបណ្ឌិតក៏ដូច្នោះដែរ កាលបើកែទៅ ក៏និងដល់ទីបំផុតសេចក្តីសុខសេចក្តីទុក្ខបាន តាមអំណាចកាលវេលា គឺ និងកន្ទងផុតសុខទុក្ខទៅបាន តាមកាលវេលាដូចពោលហើយ ។

ចប់អដ្ឋកថាសូត្រទី ៨ ដល់សូត្រទី ១០

អ ដ្ឋ ក ថា

អន្តវាសូត្រទី ១១ ជាដើម ដល់សូត្រទី ១៨

[១៦៣] *បទថា* ***អន្តវា លោកោ*** *សេចក្តីថា ទិដ្ឋិដែលកើតឡើងដោយការប្រកាន់នោះ ឬដោយការត្រិះរិះថា លោក គឺ និមិត្តដែលផ្សាយទៅបានផ្នែកមួយ (មានទីបំផុត) ។*

[១៦៤] *បទថា* ***អនន្តវា*** *សេចក្តីថា ទិដ្ឋិដែលកើតឡើងដោយការប្រកាន់នោះ ឬដោយការត្រិះរិះថា លោក គឺ និមិត្តដែលកំណត់ទំហំមិនបាន ផ្សាយទៅគ្រប់ផ្នែក (មិនមានទីបំផុត) ។*

[១៦៥] *បទថា* ***តំ ជីវំ តំ សរីរំ*** *បានដល់ ទិដ្ឋិដែលកើតឡើងថា ជីវៈ និងសរីរៈ តែមួយដូចគ្នា ។*

បទដ៏សេសគ្រប់កន្លែង មានសេចក្តីងាយនោះឯង ។

ម្យ៉ាងទៀត វេយ្យាករណ៍ទាំងនេះ មាន ១៨ យ៉ាង ដោយអំណាចសោតាបត្តិមគ្គមុន នេះជាការដល់លើកទី ១ ។

ចប់អដ្ឋកថា សោតាបត្តិវគ្គទី ១

ចប់សោតាបត្តិវគ្គ

រួមក្នុងវគ្គនេះមាន ០៧ អដ្ឋកថា

១-អដ្ឋកថា ឋានសូត្រ ២-អដ្ឋកថា ឱតំមជ្ឈលំនោច...សូត្រ

៥-អដ្ឋកថា ឆត្តិធិដ្ឋសូត្រ ៦-អដ្ឋកថា ករោតោសូត្រ

៧-អដ្ឋកថា ហេតុសូត្រ ១០-អដ្ឋកថា មហាធិដ្ឋិ ជល់អស្សុ...សូត្រ

១១-អដ្ឋកថា អន្តរាសូត្រ ជល់សូត្រទី ១៨

អ ដ្ឋ ក ថា

ទុតិយគមនាទិវគ្គ[1]

ការដល់លើកទី ២ ព្រះមានព្រះភាគត្រាស់ទុក ដោយអំណាចទុក្ខ សូម្បីក្នុងប្រការនេះ វេយ្យាករណ៍ក៏មាន ១៨ តអំពីវេយ្យាករណ៍ ១៨ នោះទៅ ក៏មានវេយ្យាករណ៍ ៨ មានជាដើមថា ***ខ្ជូនមានរូប*** *ដូច្នេះ ។ ការដល់នោះ រួមជាមួយវេយ្យាករណ៍ទាំងនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងវេយ្យាករណ៍ទី ២ ដូច្នេះឯង ។*

[១៧៦] *បណ្តាបទទាំងនោះ បទថា* ***រូបី*** *បានដល់ អារម្មណ៍ន៏ុះឯង គឺ ទិដ្ឋិដែលប្រកាន់ (អារម្មណ៍) ថា ជាអត្តា ។*

ចប់អដ្ឋកថា រូបីអត្តសូត្រទី ១៥

១-ព្រះសូត្រ ជាទុតិយចេយ្យាល ។

អដ្ឋកថា

អរូបីអត្តសូត្រនី ២០

[๑๗๘] *បទថា* ***អរូបី*** *បានដល់ ឈាន គឺ ទិដ្ឋិដែលប្រកាន់ឈានថា ជាខ្លួន ។*

ចប់អដ្ឋកថា អរូបីអត្តសូត្រនី ២០

អ ដ្ឋ ក ថា

រូបីចអរូបីអត្តសូត្រទី ២១

[១៧៩] *បទថា* **រូបី ច អរូបី ច** *បានដល់ អារម្មណ៍ និងឈាន គឺ ទិដ្ឋិដែលប្រកាន់ (អារម្មណ៍ និងឈាន) ថា ជាខ្លួន ។*

ចប់អដ្ឋកថា រូបីចអរូបីអត្តសូត្រទី ២១

អ ដ្ឋ ក ថា

នេវរូបីនារូបីអត្តសូត្រទី ២២

[១៨០] *បទថា* ***នេវរូបីនារូបី*** *បានដល់ ទិដ្ឋិដែលប្រកាន់ដោយហេតុត្រឹមតែការត្រិះរិះ ។*

ចប់អដ្ឋកថា នេវរូបីនារូបីអត្តសូត្រទី ២២

អ ដ្ឋ ក ថា

ឯកន្តសុខីសូត្រទី ២៣

[១៨១] *បទថា* **ឯកន្តសុខី** *បានដល់ ទិដ្ឋិដែលកើតឡើងដល់បុគ្គលអ្នកបានឈានហើយត្រិះរិះ (ជាតក្ខវិទ្យា) និងបុគ្គលរឭកជាតិបាន ។*

អធិប្បាយថា ទិដ្ឋិនេះ (អត្តាមានសុខដោយចំណែកតែមួយ) រមែងកើតឡើងសូម្បីដល់បុគ្គលដែលបានឈាន ធ្វើទុកក្នុងចិត្តដល់អត្តភាព ដែលមានសុខដោយចំណែកមួយក្នុងអតីត ។

ចំណែកបុគ្គលដែលត្រិះរិះ ទិដ្ឋិរមែងកើតឡើង (យ៉ាងនេះ) ថា ក្នុងបច្ចុប្បន្ន យើងមានសុខដោយចំណែកមួយ យ៉ាងណា សូម្បីក្នុងអនាគតយើងក៏ជាអ្នកមានសុខដោយចំណែកមួយ ដូច្នោះ ។

ទិដ្ឋិនេះ រមែងកើតឡើង សូម្បីដល់បុគ្គលដែលរឭកជាតិបាន គឺ រឭកដល់ភាវៈដែលជាសុខបាន ៧-៨ កប ។

ចប់អដ្ឋកថា ឯកន្តសុខីសូត្រទី ២៣

អដ្ឋកថា

ឯកន្តទុក្ខីសូត្រទី ២៤

[๑๘๒] *សូម្បីក្នុងបទថា* **ឯកន្តទុក្ខី** *ជាដើម ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ឯកន្តទុក្ខីសូត្រទី ២៤

ចប់ទុតិយបេយ្យាល

រួមមាន ๐๖ អដ្ឋកថា

๑๕-អដ្ឋកថា ទុតិយកមនាធិសូត្រ ๒๐-អដ្ឋកថា អរូបីនោសូត្រ
๒๑-អដ្ឋកថា រូបីចអរូបីចអត្តសូត្រ ๒๒-អដ្ឋកថា នេវរូបីនារូបីអត្តសូត្រ
๒๓-អដ្ឋកថា ឯកន្តសុខីសូត្រ ๒๔-អដ្ឋកថា ឯកន្តទុក្ខីសូត្រ

អ ដ្ឋ ក ថា

តតិយបេយ្យាល

[១៨៧] *បេយ្យាលទី ៣ ព្រះមានព្រះភាគត្រាស់ទុកដោយសូត្រទាំង*

នោះឯង (រួម) ២៦ សូត្រ ដោយអំណាច ***អនិច្ចំ ទុក្ខំ*** *។*

ចប់អដ្ឋកថា តតិយបេយ្យាលទី ៣

ចប់តតិយបេយ្យាល

រួមមាន ០១ អដ្ឋកថា

អ ដ្ឋ ក ថា

ចតុត្ថបេយ្យាល

[๑๘๘-๑๙๕] *ចំណែកបេយ្យាលទី ๔ គ្រាស់ទុកដោយអំណាច*

បរិវដ្ដៈ *๓ នោះឯង ។*

ចប់អដ្ឋកថា ចតុត្ថបេយ្យាល

ចប់ចតុត្ថបេយ្យាល

រួមមាន ๐๑ អដ្ឋកថា

๑-๒๖- អដ្ឋកថា ចតុត្ថបេយ្យាល

ចប់អដ្ឋកថា ទុដ្ឋិសំយុត្ត

ឱក្កន្តសំយុត្ត

អ ដ្ឋ ក ថា

ចក្ខុសុត្តាទិសូត្រទី ១-១០

[១៩៦] *គប្បីជ្រាបវិនិច្ឆ័យក្នុងឱក្កន្តសំយុត្តដូចតទៅនេះ ៖*

បទថា ***អធិមុច្ចតិ*** *បានដល់ រមែងបាន* ***សទ្ធាធិមោក្ខ*** *។*

បទថា ***ឱក្កន្តោ សម្មត្តនិយាមំ*** *បានដល់ ចូលទៅកាន់អរិយមគ្គ ។*

ដោយបទថា ***អកញ្ចេវ តាវ កាលំ កាតុំ*** *នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់សេចក្តីមិនមានអន្តរាយ (គ្រឿងរារាំង) ដល់ផល កាលមគ្គ កើតឡើងហើយ ។ ព្រោះថា កាលមគ្គកើតឡើងហើយ ដែលឈ្មោះថា ការធ្វើអន្តរាយ (គ្រឿងរារាំង) ដល់ផលមិនមាន ដោយហេតុនោះឯង ព្រះ-មានព្រះភាគទើបត្រាស់ថា ក៏បុគ្គលនេះគប្បីជាអ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សូម្បីវេលាដែលកប្បនឹងត្រូវភ្លើងឆេះ ក៏គង់មាន (ប៉ុន្តែថា) កប្បនេះនឹងមិនគប្បីត្រូវភ្លើងឆេះ ដរាបណាដែលបុគ្គលនេះ មិន*

ទាន់ធ្វើឲ្យច្បាស់នូវសោតាបត្តិផល បុគ្គលនេះ ទើបត្រូវហៅថា អ្នកតាំងនៅអស់នៃកប្ប ។

បទថា **មត្តសោ និជ្ឈានំ ខមន្តិ** សេចក្តីថា គួរដល់ការពិចារណាមើលជាប្រមាណ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង មានន័យងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ខិកន្ធសំយុត្តទី ៤

ចប់ខិក្ខន្ធសំយុត្ត

ក្នុងសំយុត្តនេះមាន ๐๑ អដ្ឋកថា

๑-អដ្ឋកថា ចក្កុសុត្តាទិសូត្រទី ๑-๑๐

ขุปฺปาทสังยุตฺต

อ ฏฺ ฐ ก ถา

สูตฺรที ๑-๑๐

[๒๐๖-๒๒๕] *พากฺยทำงอสร่กฺนงขุปฺปาทสังยุตฺต ชาก่ชฺปาสร่เหีอย*

เทาะงง ฯ

จบ่อฏฺฐกถา ขุปฺปาทสังยุตฺตที ๕

จบ่ขุปฺปาทสังยุตฺต

กฺนุงสังยุตฺตเนาะมิงมีอฏฺฐกถาเกาะ

កិលេសសំយុត្ត

អ ដ្ឋ ក ថា

សូត្រទី ១-១០

គប្បីជ្រាបវិនិច្ឆ័យក្នុង ***កិលេសសំយុត្ត*** *ដូចតទៅនេះ ៖*

[๒๒๖-๒๓๕] *បទថា* ***ចិត្តស្សូបក្កិលេសោ*** *សេចក្តីថា (ជា ឧបក្កិលេស) របស់ចិត្តដូចណា ?*

(ជាឧបក្កិលេស) របស់ចិត្តដែលប្រព្រឹត្តទៅក្នុងកូមិ ๔ ។

សួរថា (ឆន្ទរាគៈជាឧបក្កិលេស) របស់ចិត្តដែលប្រព្រឹត្តទៅក្នុង កូមិ ๓ រាប់ថាត្រឹមត្រូវ (តែ) (ជាឧបក្កិលេស) របស់លោកុត្តរចិត្តដូចម្តេច ?

ឆ្លើយថា បានព្រោះហាមការកើតឡើង (នៃលោកុត្តរចិត្ត) អធិប្បាយ ថា ឆន្ទរាគៈនោះ គប្បីជ្រាបថាជាឧបក្កិលេស ព្រោះមិនឲ្យលោកុត្តរចិត្តនោះ កើតឡើង ។

បទថា ***នេក្ខម្មនិន្នំ*** *បានដល់ (ចិត្ត) ដែលបង្អោនទៅក្នុងលោកុត្តរធម៌

๙ ។

បទថា ***ចិត្តំ*** *បានដល់ ចិត្តដែលចម្រើនសមថៈ និងចិត្តដែលចម្រើនវិបស្សនា ។*

បទថា ***អភិញ្ញា សច្ឆិករណីយេសុ ធម្មេសុ*** *សេចក្តីថា ឬកាលបុគ្គលចាប់ប្រកាន់ធម៌ណាមួយ ក្នុងបណ្តាធម៌ គឺ អភិញ្ញា ប្រការទី ៦ ដែលគប្បីដឹងហើយ ធ្វើឲ្យច្បាស់ដោយបច្ចវេក្ខណញ្ញាណ ក៏គប្បីប្រកាន់ថា* ***នេក្ខម្មៈ*** *ក៏គឺព្រះនិព្វានន៎ុះឯង ។*

បទដ៏សេសក្នុងសូត្រទាំងអស់ មានអត្ថងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា កិលេសសំយុត្ត

ចប់កិលេសសំយុត្ត

ក្នុងសំយុត្តនេះមាន ๐๑ អដ្ឋកថា

๑-អដ្ឋកថា កិលេសសំយុត្ត

សារីបុត្តសំយុត្ត

អ ដ្ឋ ក ថា

សូត្រទី ១-៩

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ នៃសារីបុត្តសំយុត្ត ដូចតទៅនេះ ៖

[២៣៦-២៤៤] *បទថា* **ន ឯវំ ហោតិ** *សេចក្តីថា ព្រោះលោកលះអហង្ការ (ការសម្គាល់ថាយើង) និងមមង្ការ (ការសម្គាល់ថារបស់យើង) បានហើយ ទើបមិនមានការគិតយ៉ាងនេះ ។*

សូម្បីក្នុងសូត្រទី ២ ជាដើម (ជាបជណ្តសូត្រទី ៩) ក៏មានន័យដូចគ្នានោះឯង ។

ចប់អដ្ឋកថា សូត្រទី ១-៩

អ ដ្ឋ ក ថា

សូចិមុខីសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ ៖

[២៤៥] *បទថា* ***សូចិមុខី*** *គឺ នាងបរិព្វាជិកាដែលមានឈ្មោះយ៉ាងនេះ។*

បទថា ***ឧបសង្កមិ*** *សេចក្តីថា នាងបរិព្វាជិកានោះ ឃើញព្រះថេរៈមានរូបស្អាត គួរពិតពិលរមិលមើល មានពណ៌សម្បុរស្អាតល្អដូចមាស ក៏មានចិត្តជ្រះថ្លាចំពោះលោក ទើបចូលទៅរកដោយគិតថា យើងនឹងធ្វើការរីករាយជាមួយព្រះថេរៈនេះ គ្រានោះ កាលព្រះថេរៈបដិសេធពាក្យនិយាយនោះ នាងទើបគិតថា ឥឡូវនេះ យើងនឹងលើកវាទៈជាមួយព្រះថេរៈនោះ ទើបពោលថា សមណៈ បើដូច្នោះ លោកងើយមុខឆាន់ឬ ?*

បទថា ***ទិសាមុខោ*** *បានដល់ បែរមុខកាន់ទិសទាំង ៤ ។ អធិប្បាយថា សម្លឹងមើលទាំង ៤ ទិស (ទិសណាមួយ) ។*

បទថា ***វិទិសាមុខោ*** *បានដល់ សម្លឹងមើលទិសឈ្ងាងទាំង ៤ ទិស ។*

បទថា ***វត្ថុវិជ្ជាតិរច្ឆានវិជ្ជាយ*** *បានដល់ តិរច្ឆានវិជ្ជា ពោលគឺ វិជ្ជា*

មើលទាយផ្ទៃដី ។ ឧបាយជាគ្រឿងជីវិតដល់ហេតុដែលធ្វើឲ្យផ្ទៃដីទាំងឡាយ មានជីចំការដាំឈ្ងោក ត្រឡាច និងដំឡូងជាដើម សម្បូរណ៌ដោយកោគផល ឈ្មោះថា **វិជ្ជាមើលផ្ទៃដី** ។

បទថា **មិច្ឆាជីវេន ជីវិកំ កប្បេន្តិ** សេចក្តីថា ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ពោលគឺ តិរច្ឆានវិជ្ជា ជានដល់ វិជ្ជាមើលជីទីនោះៗ ឯង ។

អធិប្បាយថា បរិកោគបច្ច័យដែលពួកជនអ្នកជ្រះថ្លា ព្រោះសេចក្តីសម្បូរណ៌ដោយកោគផលនៃផ្ទៃដីទាំងនោះឯង ។

បទថា **អជោមុខា** សេចក្តីថា ឈ្មោះថា ឱនមុខបរិកោគ ដោយអំណាចមើលផ្ទៃដីហើយបរិកោគ ។

ម្យ៉ាងទៀត ក្នុងបទទាំងនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **នក្ខត្តវិជ្ជា** ជានដល់ វិជ្ជាដែលជាហេតុឲ្យដឹងយ៉ាងនេះថា ថ្ងៃនេះ ឫក្សនេះ គួរទៅដោយឫក្សនេះ មិនគួរទៅដោយឫក្សនេះ គួរធ្វើវត្ថុនេះ ដោយឫក្សនេះ ។

បទថា **ទូតេយ្យំ** ជានដល់ ការងារបស់ទូត គឺ ការទទួលយកសាសន៍របស់បុគ្គលនោះៗ ទៅក្នុងទីនោះៗ ។

បទថា **បហិណគមនំ** ជានដល់ ការចូលទៅកាន់ត្រកូលមួយ ដោយ

សាសន៍របស់ត្រកូលមួយទៀត ក្នុងស្រុកជាមួយគ្នានុ៎ះឯង ។

បទថា **អគ្គវិជ្ជា** បានដល់ វិជ្ជាជាហេតុឲ្យដល់អគ្គសម្បត្តិ (លក្ខណៈអាយវៈដែលល្អ) តាមឥត្តិលក្ខណៈ និងបុរិសលក្ខណៈ ហើយជ្រាបយ៉ាងនេះថា បុគ្គលនឹងបានវត្ថុនេះ ដោយអគ្គសម្បត្តិយ៉ាងនោះ ។

បទថា **វិទិសាមុខា** សេចក្តីថា ព្រោះថា វិជ្ជាមើលអាយវៈ ឈ្មោះថាប្រព្រឹត្តទៅក្នុងទិសឈានទាំងឡាយ ព្រោះប្រារព្ធចំណែករបស់សរីរៈនោះៗប្រព្រឹត្តទៅ (ការមើលលក្ខណៈផ្សេងៗ ត្រូវបែរមុខទៅគ្រប់ទិស) ព្រោះហេតុនោះ បុគ្គលទាំងឡាយអ្នកចិញ្ចឹមជីវិតដោយវិជ្ជានោះ ទើបឈ្មោះថា ***បែរមុខកាន់ទិសឈានទាំងឡាយបរិភោគ*** ។

បទថា **ឯវមាភេចេសិ** សេចក្តីថា នាងបរិព្វាជិកា កាលពោលពាក្យជាដើមថា **ធម្មិកំ សមណ** ឈ្មោះថា ពោល (សរសើរ) គុណរបស់ព្រះសាសនាថា ជានិយ្យានិកធម៌ ។

ក៏មនុស្សទាំងឡាយ បានស្តាប់កថានោះហើយ នាំគ្នាជ្រះថ្លាក្នុងព្រះសាសនាប្រមាណ ៥០០ ត្រកូល ដូច្នេះឯង ។

ចប់អដ្ឋកថា សូចិមុខីសូត្រទី ១០

ចប់សារីបុត្តសំយុត្ត

ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សូត្រទី ១-៩ ២-អដ្ឋកថា សូចិមុខីសូត្រទី ១០

នាគសំយុត្ត

អ ដ្ឋ ក ថា

សុទ្ធកសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ***នាគសំយុត្ត សូត្រទី ១*** *ដូចតទៅនេះ ៖*

[២៤៦] *បទថា* ***អណ្ឌជា*** *ប្រែថា កើតក្នុងពង ។*

បទថា ***ជលាពុជា*** *ប្រែថា កើតក្នុងផៃ (កន្សែងកូន) ។*

បទថា ***សំសេទជា*** *ប្រែថា កើតក្នុងទីសើម ។*

បទថា ***ឧបបាតិកា*** *ប្រែថា កើត (រហ័ស) ដូចផុសឡើង ។*

ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុក ព្រោះជាហេតុកើតឡើង នៃរឿង ។ ព្រោះថា ភិក្ខុទាំងឡាយសន្ទនាគ្នាថា កំណើតនាគមានប៉ុនណាហ្ន៎? លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់នឹងអធិប្បាយកំណើតនាគឲ្យជាក់ច្បាស់ ទើបត្រាស់សូត្រនេះ ដើម្បីឲ្យបុគ្គលទាំងឡាយនឿយណាយក្នុងកំណើតនាគ ។

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

អ ដ្ឋ ក ថា

សូត្រទី ២ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង **សូត្រទី ២ ជាដើម** ដូចតទៅនេះ ៖

[២៤៨] បទថា **ភោសជ្ជកាយោ** គឺ បណ្តាយកាយដោយមិនគិតដល់អន្តរាយ ដែលកើតអំពីហ្មពស់ ។

បទថា **ទ្វយការិនោ** ប្រែថា អ្នកមានប្រក្រតីធ្វើទាំងពីរយ៉ាង អធិប្បាយថា មានប្រក្រតីធ្វើទាំងកុសល និងអកុសល ។

បទថា **សចជ្ជ មយំ** សេចក្តីថា ប្រសិនបើថ្ងៃនេះ យើងទាំងឡាយ ។

[២៥២] បទថា **សហព្យតំ ឧបប្បជ្ជតិ** សេចក្តីថា ដល់ភាពជាអ្នក (នៅ) រួមគ្នា (សហភាព) ។ អកុសលជាបច្ច័យឲ្យបុគ្គលនោះកើតឡើងក្នុងកំណើតនាគនោះ (ចំណែក) កុសលជាបច្ច័យឲ្យនាគទាំងឡាយដែលកើតមកហើយសម្បុរណ៍ ។

[២៥៦] បទថា **អន្ទុំ** បានដល់ របស់ទំពាររបស់ស៊ី ។

បទថា **បានំ** បានដល់ ទឹកផឹកគ្រប់ប្រភេទ ។

បទថា **វត្ថំ** បានដល់ សំពត់ស្បៃក សំពត់ដណ្តប់ ។

បទថា **យានំ** បានដល់ បច្ច័យដែលជួយក្នុងការដើរផ្លូវគ្រប់ប្រភេទ ចាប់តាំងពីឆ័ត្រ និងស្បែកជើង ។

បទថា **មាលំ** បានដល់ ផ្កាឈើគ្រប់ប្រភេទ ដូចជា ផ្កាម្ទិះជាដើម ។

បទថា **គន្ធំ** បានដល់ គ្រឿងលាបគ្រប់ប្រភេទ ដូចជា ខ្ទឹមចន្ទនជាដើម ។

បទថា **សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ**[1] សេចក្តីថា ឲ្យទីដេក មានគ្រែ និងតាំងជាដើម ឲ្យទីនៅអាស្រ័យ មានផ្ទះមួយជាន់ជាដើម (និង) ឲ្យឧបករណ៍ប្រទីប មានចង្កៀង និងប្រេងជាដើម ។

ក៏នាគទាំងនោះ ធ្វើសេចក្តីប្រាថ្នាដើម្បីឲ្យមានអាយុវែង មានពណ៌សម្បុរស្អាតល្អ និងច្រើនទៅដោយសេចក្តីសុខ ហើយឲ្យទានទាំង ១០ យ៉ាងនេះ ទើបកើតក្នុងកពនាគនោះ ហើយសោយសម្បត្តិនោះឯង ។

បទដ៏សេសគ្រប់សូត្រ ក៏មានន័យងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សូត្រទី ២ ជាដើម

ចប់នាគសំយុត្ត

ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សុទ្ធកសូត្រទី ១ ២-អដ្ឋកថា សូត្រទី ២ ជាដើម

---

[1] ចាលីអដ្ឋកថា សេយ្យាវសថបទីបេយ្យំ ។

សុបណ្ណសំយុត្ត

អ ដ្ឋ ក ថា

សុទ្ធកសូត្រទី ១

[២៥៨] *គប្បីជ្រាបវិនិច្ឆ័យក្នុង* ***សុបណ្ណសំយុត្ត*** *ដូចតទៅនេះ ៖*

គ្រុឌទាំងឡាយហៅថា ***សុបណ្ណ*** *ព្រោះស្ងាបមានពណ៌ល្អ ។ សូត្រទី ១ ក្នុងសុបណ្ណសំយុត្តនេះ ព្រះមានព្រះភាគទ្រង់គ្រាស់ទុក ព្រោះជាហេតុកើតឡើងនៃរឿង តាមន័យដំបូងនុ៎ះឯង ។*

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

អ ដ្ឋ ក ថា

ហារតិសូត្រទី ២

[២៥៩] បទថា **ហរន្តិ** ប្រែថា នាំយកទៅ ។ ក៏គ្រុឌទាំងនោះ កាលនឹងនាំយក ក៏នឹងអាចនាំយកតែពួកនាគដែលមិនស្មើនឹងខ្លួន ឬដែលស្មើនឹងខ្លួន (ប៉ុណ្ណោះ) (តែ) មិនអាចនាំយកពួកនាគដែលប្រណីតជាងខ្លួន ទៅបាន ។

ក៏ឈ្មោះថា នាគ ដែលគ្រុឌនាំយកទៅមិនបាន មាន ៧ ពួក គឺ នាគដែលមានជាតិខ្ពស់ជាង មួយពួក , នាគកម្ពលអស្សតរ មួយពួក , នាគ-ធតរដ្ឋ មួយពួក , នាគដែលនៅក្នុងមហាសមុទ្រសត្តសីទន្តរៈ មួយពួក , នាគដែលនៅលើផែនដី មួយពួក , នាគដែលនៅត្រង់ភ្នំ មួយពួក , នាគដែលនៅក្នុងវិមាន មួយពួក ។

បណ្តានាគទាំងនោះ នាគដែលជាជលាពុជៈកំណើតជាដើម ខ្ពស់ជាង នាគដែលជាអណ្ឌៈកំណើតជាដើម នាគដែលជាជលាពុជៈកំណើតជាដើម ទាំងនោះ ដែលគ្រុឌទាំងនោះ នាំយកទៅមិនបាន ។ ចំណែកនាគពួកកម្ពលអស្សតរ ជានាគសេនាបតី គ្រុឌទាំងឡាយឃើញនាគទាំងនោះក្នុងទី

ណាទីមួយហើយ ក៏មិនអាចនឹងឆាបយកទៅបាន ។ នាគធតវដ្ដ ជានាគរាជាសូម្បីនាគធតវដ្ដទាំងនោះ គ្រុឌពួកណាក៏មិនអាចនឹងឆាបយកទៅបាន ។

ចំណែកនាគពួកណា នៅក្នុងមហាសមុទ្រសត្តសីទន្តរៈ គ្រុឌពួកណាក៏មិនអាចនឹងឆាបយកនាគទាំងនោះទៅបាន ព្រោះហេតុដែលនរណាៗ មិនអាចនឹងធ្វើឲ្យញាប់ញ័របានក្នុងទីណាៗ (ក្នុងមហាសមុទ្រសត្តសីទន្តរៈនោះ) ។

ចំពោះពួកនាគដែលនៅតាមផែនដីជាដើម នឹងមានឱកាសដែលគេចលាក់ខ្លួន ដូច្នោះ គ្រុឌទើបមិនអាចនឹងឆាបយកនាគទាំងនោះទៅបាន ។

ចំណែកនាគពួកណានៅលើខ្នងរលកក្នុងមហាសមុទ្រ ដែលមានសភាពស្មើគ្នា ឬប្រណីតជាងគ្រុឌ គ្រុឌមិនអាចឆាបយកនាគទាំងនោះទៅបាន ។ បទដ៏សេស មានន័យដូចពោលហើយក្នុងនាគសំយុត្តនុ៎ះឯង ។

ចប់អដ្ឋកថា ហារតិសូត្រទី ២

ចប់សុបណ្ណសំយុត្ត

ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សុទ្ធកសូត្រទី ១ ២-អដ្ឋកថា ហារតិសូត្រទី ២

គន្ធព្វកាយសំយុត្ត

អ ដ្ឋ ក ថា

សុទ្ធកសូត្រទី ១

[២៦៤] *គប្បីជ្រាបវិនិច្ឆ័យក្នុង* ***គន្ធព្វកាយសំយុត្ត*** *ដូចតទៅនេះ ៖*

បទថា ***មូលគន្ធេ អធិវត្ថា*** *សេចក្តីថា ដើមឈើណាមានក្លិននៅត្រង់ឫស ទេវតាអាស្រ័យដើមឈើនោះកើត ។ ក៏ដើមឈើសូម្បីទាំងអស់នោះ រមែងសម្រេចប្រយោជន៍ដល់ទេវតាទាំងនោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យដូចគ្នានេះឯង ។*

បទថា ***គន្ធគន្ធេ*** *បានដល់ ក្លិន បណ្តាក្លិន មានក្លិនកើតអំពីឫសជាដើម ។*

ក៏ចំណែកទាំងអស់ មានឫសជាដើមរបស់ដើមឈើណា មានក្លិនដើមឈើនោះឈ្មោះ ***គន្ធៈ*** *ក្នុងទីនេះ ត្រង់ក្លិនរបស់ដើមឈើដែលមានក្លិននោះ ។ ទេវតាស្ថិតនៅត្រង់ដើមឈើដែលមានក្លិននោះ ។ ក្នុងទីនេះ ចំណែកទាំងអស់ មានឫសជាដើម រមែងសម្រេចប្រយោជន៍ដល់ទេវតាទាំងនោះឯង ។*

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

អដ្ឋកថា

មូលគន្ធទាតាសូត្រទី ៣

[២៦៦] បទថា ***សោ ទាតា ហោតិ មូលគន្ធានំ*** សេចក្តីថា គេជាអ្នកឲ្យទាន ក្នុងឫសឈើ មានក្នុងលំពាន់ជាដើម ។ គប្បីជ្រាបសេចក្តីក្នុងគ្រប់បទយ៉ាងនេះ ។

ក៏ទេវតាទាំងឡាយ (កាលនៅជាមនុស្ស) ឲ្យទាន ដែលមានផលដូចគ្នានឹងវត្ថុដែលឲ្យហើយ តាំងសេចក្តីប្រាថ្នា (ដែលនឹងបានមកទទួលផលទាននេះ) ទុក ដោយប្រការដូចពណ៌នាមកដូច្នេះ ។ ដើម្បីនឹងសម្តែង សូម្បីទានដែលឲ្យផលមិនដូចគ្នានឹងវត្ថុដែលឲ្យនោះ ព្រះមានព្រះភាគទើបត្រាស់វត្ថុទាន ១០ យ៉ាងទុក មានជាដើមថា ***សោ អន្នំ ទេតិ*** (បុគ្គលឲ្យបាយ) ។ បទដ៏សេសក្នុងគ្រប់សូត្រ ក៏មានន័យងាយទាំងនោះឯង ។

ចប់អដ្ឋកថា មូលគន្ធទាតាសូត្រទី ៣

ចប់គន្ធកាយសំយុត្ត

ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សុទ្ធកសូត្រទី ១ ២-អដ្ឋកថា មូលគន្ធទាតាសូត្រទី ៣

វលាហកសំយុត្ត

អ ដ្ឋ ក ថា

ទេសនាសូត្រទី ១

[២៧០] *គប្បីជ្រាបវិនិច្ឆ័យក្នុង* ***វលាហកសំយុត្ត*** *ដូចតទៅនេះ ៖*

បទថា ***វលាហកកាយិកា*** *បានដល់ ទេវតាដែលអណ្តែតទៅក្នុងអាកាស ដែលកើតឡើងក្នុងពួកទេព នាមថា* ***វលាហកៈ*** *។*

បទថា ***សីតវលាហកា*** *បានដល់ ទេវតាវលាហកៈ (ទេវាពពក) ដែលបណ្តាលឲ្យកើតភាពត្រជាក់ ។*

សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះឯង ។

ចប់អដ្ឋកថា ទេសនាសូត្រទី ១

អដ្ឋកថា

សូត្រទី ១៣-៥២

[២៧៧] បទថា **ចេតោបណិធិមន្វាយ** សេចក្តីថា អាស្រ័យការតាំងចិត្ត ។

បទថា **សីតំ ហោតិ** សេចក្តីថា កាពត្រជាក់ណាមានក្នុងវស្សានរដូវ និងហេមន្តរដូវ កាពត្រជាក់នោះ មានរដូវជាសមុដ្ឋាននោះឯង ។ ចំណែកកាពត្រជាក់ ដែលត្រជាក់ខ្លាំងជាងកាពត្រជាក់ទាំងឡាយ និងកាពត្រជាក់ដែលកើតឡើងក្នុងគិម្ហន្តរដូវណា កាពត្រជាក់នោះ ចាត់ជាកាពត្រជាក់ដែលកើតឡើងដោយអានុភាពរបស់ទេវតា ។

ចប់អដ្ឋកថា សូត្រទី ១៣-៥២

អ ដ្ឋ ក ថា

សូត្រទី ៥៣

[២៧៨] បទថា **ឧណ្ហំ ហោតិ** សេចក្តីថា ជាតុក្តៅក្នុងគិម្ហន្តរដូវណា ជាតុ ក្តៅនោះ ជាជាតុក្តៅប្រក្រតី (ធម្មតា) នុ៎ះឯង មានរដូវជាសមុដ្ឋាន ចំណែកជាតុក្តៅដែលមានសូម្បីក្នុងរដូវក្តៅ និងជាតុក្តៅ ដែលមានក្នុងរដូវត្រជាក់ ឈ្មោះថា ជាជាតុក្តៅដែលកើតឡើងដោយអានុភាពរបស់ទេវតា ។

ចប់អដ្ឋកថា សូត្រទី ៥៣

អដ្ឋកថា

សូត្រទី ៥៤

[២៧៩] បទថា **អព្ភំ ហោតិ** សេចក្តីថា មានមណ្ឌបពពក (ក្រុមពពក) ។ សូម្បីក្នុងសូត្រនេះ ពពកដែលបង្កើនឡើងក្នុងវស្សានរដូវ (រដូវក្តៅ) និងក្នុងសិសិរដូវ (រដូវរងារ) ជាពពកតាមប្រក្រតី (ធម្មតា) នុ៎ះឯង មានរដូវជាសមុដ្ឋាន ។

ចំណែកពពកក្រាស់ ក្នុងរដូវមានពពកនុ៎ះឯង ដែលបិទបាំងព្រះចន្ទ និងព្រះអាទិត្យ ធ្វើឲ្យងងឹតងងុល អស់វេលា ៧ សប្តាហ៍ និងពពកក្នុងខែ ៥ ខែ ៦ ឈ្មោះថា ពពកដែលកើតឡើងដោយអានុភាពរបស់ទេវតា ។

ចប់អដ្ឋកថា សូត្រទី ៥៤

អ ដ្ឋ ក ថា

អព្ភវលាហកសូត្រទី ៥៥

[២៧៩] បទថា **ភាគោ ហោតិ** សេចក្តីថា ខ្យល់តាមប្រក្រតីដែលបក់មកពីទិសខាងជើង និងទិសខាងត្បូងជាដើម ដែលមានក្នុងរដូវនោះ នេះជាខ្យល់មានរដូវជាសមុដ្ឋានទុំ៎ះឯង ចំណែកខ្យល់កម្ចាំងដែលបក់ទម្លាយដើមឈើជាដើម និងខ្យល់ដែលកើតឡើងខុសរដូវកាល ខ្យល់ដទៃនេះឈ្មោះថាខ្យល់ ដែលកើតដោយអានុភាពទេវតា ។

ចប់អដ្ឋកថា អព្ភវលាហកសូត្រទី ៥៥

អ ដ្ឋ ក ថា

ទារុណវលាហកសូត្រទី ៥៦

[២៨១] បទថា **ទេវោ វស្សតិ** សេចក្តីថា ភ្លៀងដែលធ្លាក់រហូតអស់ ៤ ខែ ក្នុងរដូវភ្លៀង ក៏មានខុតុជាសមុដ្ឋាននោះឯង ។ ចំណែកភ្លៀងជោគជាំ ដែលធ្លាក់ក្នុងរដូវភ្លៀង និងភ្លៀងក្នុងខែ ៥ ខែ ៦ ឈ្មោះថា កើតឡើងដោយ អានុភាពទេវតា ។

ក្នុងសេចក្តីនោះ មានរឿងនេះជាតួយ៉ាង ៖

បានឮមកថា វស្សវលាហកទេវបុត្រមួយអង្គ ទៅរកព្រះថេរៈដែល ទីណាស្រេព ដែលចាំវស្សានៅក្នុងកុដិឈើក្រឹស្នា ហើយបានឈរខាងក្រៅ ។

ព្រះថេរៈសួរថា អ្នកជាអ្នកណា ?

ខ្ញុំគឺ វស្សវលាហកទេវបុត្រ លោកម្ចាស់ ។

ជ្រាបថា ដោយអំណាចចិត្តរបស់អ្នក ធ្វើឲ្យភ្លៀងធ្លាក់បានឬ ?

ត្រូវហើយ លោកម្ចាស់

ពួកអាត្មា ចង់ឃើញ

លោកម្ចាស់នឹងទទឹកជាមិនខាន លោកម្ចាស់

ជុំពពកធំ ឬសំឡេងនេះ មិនប្រាកដឡើយ ពួកយើងនឹងទទឹកបានយ៉ាងណា ?

លោកម្ចាស់អំណាចចិត្តរបស់ខ្ញុំ ធ្វើឲ្យក្អៀងធ្លាក់បាន សូមនិមន្តលោកម្ចាស់ចូលបណ្ណសាលាចុះ

ប្រពៃហើយ ទេវបុត្រ ព្រះថេរៈទទួលពាក្យហើយលាងជើង ចូលកាន់បណ្ណសាលា ។ កាលព្រះថេរៈនោះកំពុងចូលទៅ ទេវបុត្រក៏ច្រៀងចម្រៀងមួយបទ ហើយលើកដៃឡើង ។ ពេលនោះមានជុំពពកមួយជុំ តាំងឡើងជុំវិញស្ថានទីប្រមាណ ៣ យោជន៍ (ធ្វើឲ្យកើតក្អៀង) ព្រះថេរៈទទឹកខ្លួនពាក់កណ្តាល ចូលទៅកាន់បណ្ណសាលា ។

ម្យ៉ាងទៀត ឈ្មោះថា ក្អៀងនេះ នឹងឈប់ធ្លាក់ក៏ព្រោះហេតុ ៨ ប្រការ គឺ ព្រោះអានុភាពរបស់នាគ ១ ព្រោះអានុភាពរបស់គ្រុឌ ១ ព្រោះអានុភាពរបស់ទេវតា ១ ព្រោះមានឧតុជាសមុដ្ឋាន ១ ព្រោះមារបណ្តាល ១ ព្រោះកម្មាំងឫទ្ធិ ១ ព្រោះមេឃប្រល័យកប្ប (ពពកដែលញាំងកប្បឲ្យវិនាស) ១ ។

ចប់អដ្ឋកថា វាតវលាហកសូត្រទី ៥៦

ចប់ឥសាហកសំយុត្ត

ក្នុងសំយុត្តនេះមាន ០៦ អដ្ឋកថា

១-អដ្ឋកថា ឧទេសធាស្វត្រនី ១	២-អដ្ឋកថា ស្វត្រនី ១៣-៥២
៣-អដ្ឋកថា ស្វត្រនី ៥៣	៤-អដ្ឋកថា ស្វត្រនី ៥៤
៥-អដ្ឋកថា ស្វត្រនី ៥៥	៦-អដ្ឋកថា ស្វត្រនី ៥៦

វច្ឆគោត្តសំយុត្ត

អ ដ្ឋ ក ថា

វច្ឆគោត្តសំយុត្ត

[២៨២-៣១២] *គប្បីជ្រាបវិនិច្ឆ័យក្នុង* ***វច្ឆគោត្តសំយុត្ត*** *ដូចតទៅនេះ ៖*

បទថា ***អញ្ញោតេ*** *ប្រែថា ព្រោះមិនដឹង ។*

គប្បីជ្រាបអត្ថក្នុងគ្រប់បទ ដោយអំណាចជាតតិយាវិភត្តិដូចគ្នា ដូចពណ៌នាមកដូច្នេះ ។ ក៏បទទាំងនេះគ្រប់បទ ជាវេវចនៈនៃគ្នានិងគ្នានុ៎ះឯង ។

ក៏ឯក្នុងសំយុត្តនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សូត្រទុក ១១ សូត្រ ត្រាស់វេយ្យាករណ៍ទុក ៥៥ វេយ្យាករណ៍ ។

ចប់វច្ឆគោត្តសំយុត្ត

ក្នុងសំយុត្តនេះមាន ០១ អដ្ឋកថា

សមាធិសំយុត្ត

អ ដ្ឋ ក ថា

សមាធិសមាបត្តិសូត្រទី ១

[៣១៣] *គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ នៃ* ***សមាធិសំយុត្ត*** *ដូចតទៅនេះ ៖*

បទថា ***សមាធិកុសលោ*** *សេចក្តីថា ជាអ្នកឆ្លាតក្នុងការកំណត់អង្គយ៉ាងនេះគឺ បឋមជ្ឈានមានអង្គ ៥ ។*

បទថា ***ន សមាបត្តិកុសលោ*** *សេចក្តីថា មិនអាចធ្វើចិត្តឲ្យរីករាយឲ្យអាច ហើយចូលឈានបាន ។*

គប្បីជ្រាបបទដ៏សេសដោយន័យនេះ ។

ចប់អដ្ឋកថា សមាធិសមាបត្តិសូត្រទី ១

អ ដ្ឋ ក ថា

ឋិតិសូត្រទី ២

[៣១៤] *គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ២ ជាដើម ដូចតទៅនេះ ៖*

បទថា ***ន សមាធិស្មិ ឋិតិកុសលោ*** *សេចក្តីថា មិនឆ្លាតក្នុងការបញ្ឈប់ឈានទុកបាន គឺ មិនអាចនឹងបញ្ឈប់ឈានទុកបានដោយត្រឹមតែផ្ទាត់ ៧-៨ ម្រាមដៃ ។*

ចប់អដ្ឋកថា ឋិតិសូត្រទី ២

អដ្ឋកថា

វុដ្ឋានសូត្រទី ៣

[៣១៥] បទថា ***ន សមាធិស្មិំ វុដ្ឋានកុសលោ*** សេចក្តីថា មិនឆ្លាតក្នុងការចេញចាកឈាន គឺ មិនអាចនឹងចេញបានតាមវេលាដែលកំណត់ទុក ។

ចប់អដ្ឋកថា វុដ្ឋានសូត្រទី ៣

អ ដ្ឋ ក ថា

កល្ហិតសូត្រទី ៤

[៣១៦] បទថា **ន សមាធិស្មឹ កល្ហិតកុសលោ** សេចក្តីថា មិនឆ្លាតដែលគប្បីញុំាងចិត្តឲ្យរីករាយហើយ ធ្វើឲ្យអាច ។

ចប់អដ្ឋកថា កល្ហិតសូត្រទី ៤

អដ្ឋកថា

អារម្មណសុត្តទី ៥

[๓๑๗] *បទថា* ***ន សមាធិស្មឹ អារម្មណកុសលោ*** *សេចក្តីថា មិនឆ្លាតក្នុងអារម្មណ៍ គឺ កសិណ ។*

ចប់អដ្ឋកថា អារម្មណសុត្តទី ៥

អ ដ្ឋ ក ថា

គោចរសូត្រទី ៦

[៣១៨] *បទថា* ***ន សមាធិស្មឹ គោចរកុសលោ*** *សេចក្តីថា មិនឆ្លាត ក្នុងអារម្មណ៍របស់កម្មដ្ឋាន និងក្នុងទីមិនគោចរដើម្បីកិក្ខាចារ ។*

ចប់អដ្ឋកថា គោចរសូត្រទី ៦

អដ្ឋកថា

អភិនីហារសូត្រទី ៧

[๓๑๙] *បទថា* ***ន សមាធិស្មិំ អភិនីហារកុសលោ*** *សេចក្តីថា មិនឆ្លាតក្នុងការនាំកម្មដ្ឋានឲ្យខ្ពស់ឡើងទៅ ។*

ចប់អដ្ឋកថា អភិនីហារសូត្រទី ៧

អ ដ្ឋ ក ថា

សក្ករុការីសូត្រទី ៨

[๓๒๐] បទថា **ន សមាធិស្មឹ សក្ករុការី** សេចក្តីថា មិនមែនអ្នកមានប្រក្រតីធ្វើដោយគោរព ដើម្បីធ្វើឈានឲ្យសម្រេចអប្បនា ។

ចប់អដ្ឋកថា សក្ករុការីសូត្រទី ៨

អ ដ្ឋ ក ថា

សាតច្ចការីសូត្រទី ៩

[៣២១] *បទថា* ***ន សមាធិស្មិំ សាតច្ចការី*** *សេចក្តីថា មិនមែនជាអ្នកមានប្រក្រតីធ្វើជាប់តគ្នា ដើម្បីចេញចាកឈាន គឺ ធ្វើគ្រាខ្លះ ពេលខ្លះប៉ុណ្ណោះ ។*

ចប់អដ្ឋកថា សាតច្ចការីសូត្រទី ៩

អ ដ្ឋ ក ថា

សប្បាយការីសូត្រទី ๑๐

[๓๒๒] *បទថា* ***ន សមាធិស្មិ សប្បាយការី*** *សេចក្តីថា មិនអាចនឹងធ្វើធម៌ដែលជាទីសប្បាយ គឺ ជាឧបការៈដល់សមាធិឲ្យបរិបូណ៌បាន ។*

ចប់អដ្ឋកថា សប្បាយការីសូត្រទី ๑๐

ចប់សមាធិសំយុត្ត

ក្នុងសំយុត្តនេះមាន ๑๐ អដ្ឋកថា

๑-អដ្ឋកថា សមាធិសមាបត្តិសូត្រ
๒-អដ្ឋកថា ឋិតិសូត្រ
๓-អដ្ឋកថា វុដ្ឋានសូត្រ
๔-អដ្ឋកថា កល្យិតសូត្រ
๕-អដ្ឋកថា អារម្មណសូត្រ
๖-អដ្ឋកថា គោចរសូត្រ
๗-អដ្ឋកថា អភិនីហារសូត្រ
๘-អដ្ឋកថា សក្កច្ចការីសូត្រ
๙-អដ្ឋកថា សាតច្ចការីសូត្រ
๑๐-អដ្ឋកថា សប្បាយការីសូត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ